OFFICIAL BUSINESS

SECURITY COMPANIES AND AUTHORITIES AT SCAMMING COMPOUNDS IN CAMBODIA

សេចក្តីសង្ខេប

AMNESTY INTERNATIONAL

Amnesty International is a movement of 10 million people which mobilizes the humanity in everyone and campaigns for change so we can all enjoy our human rights. Our vision is of a world where those in power keep their promises, respect international law and are held to account. We are independent of any government, political ideology, economic interest or religion and are funded mainly by our membership and individual donations. We believe that acting in solidarity and compassion with people everywhere can change our societies for the better.

© Amnesty International 2026
Except where otherwise noted, content in this document is licensed under a Creative Commons (attribution, non-commercial, no derivatives, international 4.0) licence.
https://creativecommons.org/licenses/by-nc-nd/4.0/legalcode
For more information please visit the permissions page on our website: www.amnesty.org
Where material is attributed to a copyright owner other than Amnesty International this material is not subject to the Creative Commons licence.
First published in 2026
by Amnesty International Ltd
Peter Benenson House, 1 Easton Street
London WC1X 0DW, UK

Index: ASA 23/1569/2026
Original language: English

amnesty.org

Cover image: The illustration shows a security guard standing inside a scamming compound where people are tortured and forced to conduct online scams, illustrated by Colin Foo

AMNESTY INTERNATIONAL

មាតិកា

1.	**សេចក្តីសង្ខេប**	**4**
1.1	វិធីសាស្ត្រ	6
1.2	សាវតា	8
1.3	តួនាទីរបស់បុគ្គលិកសន្តិសុខ	8
1.4	ការធានាប្រាក់ចំណេញ	10
1.5	ទំនាក់ទំនងកងកម្លាំងយោធា និងមន្ត្រីប៉ូលីស ទៅនឹងទីតាំងប្រព្រឹត្តអំពើឆបោក	13
1.6	ក្របខ័ណ្ឌច្បាប់ និងការវិភាគ	16
1.7	សេចក្តីសន្និដ្ឋាន	19
1.8	អនុសាសន៍	19

1. សេចក្តីសង្ខេប

> **«ពួកគេនឹងចូលមកប្រើខ្ញុំ ក្នុងពេលដែលសន្តិសុខឈរយាមនៅមាត់ទ្វារ»។**

Maia (មិនមែនឈ្មោះពិត) បានធ្វើដំណើរមកប្រទេសកម្ពុជា ដោយគិតថានាងនឹងបានធ្វើការនៅសណ្ឋាគារមួយ។ នាងគិតថា នាងអាចរកប្រាក់បានគ្រប់គ្រាន់ដើម្បីផ្ញើឲ្យកូនៗនាងនៅផ្ទះ។ អ្នកបើកបរម្នាក់បានមកយកនាងនៅព្រលានយន្តហោះ ប៉ុន្តែ ក្រោយពេលជិះជាច្រើនម៉ោងនៅក្នុងរថយន្ត នាងចាប់ផ្តើមព្រួយបារម្ភថា តើគេយកនាងទៅទីណា។ នៅពេលដែលនាងបាន ទៅដល់ទីតាំងប្រព្រឹត្តអំពើឆបោកដែលគេស្គាល់ថា “Park 8” (PV01[1]) នាងដឹងភ្លាមៗថាមានអ្វីខុសពីធម្មតា។ រថយន្តដែល នាងជិះត្រូវបានបើកកាត់តាមច្រកទ្វារដោយមានសន្តិសុខពិនិត្យស្លាកលេខ និងដឹកនាំចរាចរណ៍។ ពួកគេពាក់ឯកសណ្ឋានពណ៌ ខ្មៅ ហើយពួកគេភាគច្រើនបានបិទមុខ។ នៅពេលនាងចេញពីឡាន នាងត្រូវបានគេនាំទៅកាន់ការិយាល័យមួយ ដោយមាន សន្តិសុខពីរនាក់ក្រៀកដៃនាងម្នាក់ម្ខាង ហើយចៅកែបានប្រាប់នាងឱ្យចុះកិច្ចសន្យា។

សន្តិសុខបានយក Maia ទៅបន្ទប់របស់នាង។ គ្រប់កន្លែងដែលនាងទៅ ក្នុងទីតាំងប្រព្រឹត្តអំពើឆបោកនោះ តែងតែមានសន្តិ សុខនៅក្បែរនៅចាំមើល។ នៅពេលដែលអ្នកនៅក្នុងនោះបង្កបញ្ហាដល់ចៅកែ ដូចជាមិនចង់ធ្វើការ សន្តិសុខនឹងចូលទៅក្នុង បន្ទប់ដោយមានដំបងឆក់ ហើយធ្វើអ្វីដូចដែលចៅកែប្រាប់ឱ្យពួកគេធ្វើ។

Maia ត្រូវបានផ្តល់ភារកិច្ចឱ្យទាក់ទង និងធ្វើការឆបោកពលរដ្ឋអាមេរិក។ ក្រុមហ៊ុនបានកំណត់គោលដៅឆបោកលើជនជាតិ អាមេរិក។ នៅពេលដែលនាងមិនបានសម្រេចតាមគោលដៅការងាររបស់នាង សន្តិសុខម្នាក់បាននាំនាងទៅបន្ទប់ងងឹតមួយ ហើយចាក់សោទ្វារ។ នៅពេលដែលអ្នកគ្រប់គ្រងមកដល់បន្ទប់ងងឹតនោះដើម្បីចាប់រំលោភនាង ទ្វារត្រូវបានបើកដោយសន្តិសុខ ដែលឈរយាម នៅពេលដែលអ្នកគ្រប់គ្រងទាំងនោះចាប់រំលោភនាង។

---

1. អង្គការលើកលែងទោសអន្តរជាតិ ប្រើប្រាស់លេខកូដដើម្បីសំដៅទៅលើទីតាំងដែលប្រើប្រាស់សម្រាប់ការប្រព្រឹត្តអំពើឆបោក។ ឧទាហរណ៍មួយគឺលេខកូដ “PV01”។ ការប្រើប្រាស់លេខកូដត្រូវតម្រូវឱ្យមាន ដោយសារទីតាំងទាំងនោះត្រូវបានគេហៅដោយឈ្មោះផ្សេងៗគ្នា ដែលភាគច្រើនមិនមែនជាឈ្មោះផ្លូវការ ហើយអាច បង្កឱ្យមានការភាន់ច្រឡំ។ ក្នុងករណីដែលជនរងគ្រោះជាច្រើនហៅទីតាំងណាមួយដោយប្រើឈ្មោះដូចគ្នា អង្គការលើកលែងទោសអន្តរជាតិ នឹងប្រើឈ្មោះនោះ រួមជាមួយ លេខកូដដែលអង្គការបានកំណត់សម្រាប់ទីតាំងនោះ ឧទាហរណ៍ “Park 8” (ឈ្មោះ) និង “PV01” (លេខកូដ)។ រាល់លេខកូដសម្រាប់ទីតាំងទាំងនេះ ព្រមទាំង ព័ត៌មានលម្អិតអំពីទីតាំងនីមួយៗ អាចរកបាននៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍មុនៗរបស់អង្គការលើកលែងទោសអន្តរជាតិ ស្តីពីទីតាំងប្រព្រឹត្តអំពើឆបោកនៅក្នុង ប្រទេសកម្ពុជា។ សូមមើលរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ ក្រោមចំណងជើងថា “I Was Someone Else’s Property”: Slavery, Human Trafficking and Torture in Cambodia’s Scamming Compounds” (“ខ្ញុំគឺជាទ្រព្យសម្បត្តិរបស់អ្នកដទៃ”៖ ទាសភាព ការជួញដូរមនុស្ស និងការធ្វើទារុណកម្ម នៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោកនៅកម្ពុជា) (លេខយោង៖ ASA 23/9447/2025) ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥ https://www.amnesty.org/en/documents/asa23/9447/2024/en/ (ហៅថា Someone Else’s Property - ទ្រព្យសម្បត្តិរបស់អ្នកដទៃ) និងរបាយការណ៍ របស់អង្គការលើកលែងទោសអន្តរជាតិ ចំណងជើងថា “Falling Through the Cracks: Cambodia’s “Crackdown” on Scamming Compounds and the Victims it has Failed” (បរាជ័យក្នុងការបង្ក្រាប៖ បរាជ័យនៃ “ការបង្ក្រាប” លើទីតាំងប្រព្រឹត្តអំពើឆបោក និងការជួយដល់ជនរងគ្រោះ របស់កម្ពុជា) (លេខយោង៖ ASA 23/1093/2026) ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦ https://www.amnesty.org/en/documents/ASA23/1093/2026/en/ (ហៅថា Falling Through the Cracks - បរាជ័យក្នុងការបង្ក្រាប)។

Maia ត្រូវបានគេរំលោភបីដងក្នុងបន្ទប់ងងឹតនោះ។ នាងមិនមែនជាមនុស្សតែម្នាក់ទេដែលត្រូវបានគេរំលោភ។ អង្គការលើកលែងទោសអន្តរជាតិបាននិយាយជាមួយអ្នកដែលបានរួចខ្លួនបីនាក់ផ្សេងទៀតដែលមកពីទីតាំង Park 8 ដែលពួកគេក៏ត្រូវបានគេរំលោភ ពេលដែលនៅក្នុងទីតាំងនោះដែរ។

Maia ចាំបានថា សន្តិសុខមានប្រដាប់ដោយដំបងឆក់ និងកាំភ្លើងខ្លី ហើយមានអ្នកខ្លះមានកាំភ្លើងធំជាង។ នាងថែមទាំងបាននិយាយថា មានមនុស្សដែលមើលទៅហាក់ដូចជាពួកគេបំរើការនៅក្នុងជួរយោធា បានមកទីតាំងប្រព្រឹត្តអំពើឆបោកនោះនៅពេលដែលថៅកែមក។ នៅពេលបង្ហាញរូបភាពនៃទីតាំងប្រព្រឹត្តអំពើឆបោក Park 8 នាងចំណាំបានច្រកទ្វារ និងអគារ។ ហើយនៅពេលដែលបង្ហាញរូបភាពរបស់សន្តិសុខនៅទីតាំងនោះ នាងបានកំណត់អត្តសញ្ញាណបុគ្គលម្នាក់ពីរូបថតមួយ។ ក្នុងអំឡុងពេលនៃការបង្ក្រាបនៅខែកក្កដា ឆ្នាំ២០២៥ របស់រដ្ឋាភិបាល នាងបានរត់គេចខ្លួន នៅពេលដែលថៅទីតាំងប្រព្រឹត្តអំពើឆបោកនោះក៏រត់គេចខ្លួនដែរ។

ក្រុមហ៊ុនសន្តិសុខ ស៊ីឃ្យូរីធី វីស្ស៊ីន ដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះ ជាក្រុមហ៊ុនដែលបានផ្តល់សេវាសន្តិសុខនៅទីតាំងប្រព្រឹត្តអំពើឆបោក Park 8 ។

បទពិសោធន៍របស់ Maia ជាផ្នែកមួយនៃឯកសារដែលត្រូវបានចងក្រង ដែលវាឆ្លុះបញ្ចាំងពីរបៀបដំណើរការនៃឧស្សាហកម្មប្រព្រឹត្តអំពើឆបោកទូទាំងប្រទេសកម្ពុជា។

Maia’s story, illustration by Colin Foo.

អង្គការលើកលែងទោសអន្តរជាតិបានកត់ត្រាអំពីវត្តមានរបស់សន្តិសុខឯកជនដែលធ្វើប្រតិបត្តិការនៅទីតាំងប្រព្រឹត្តអំពើឆបោកទាំងអស់៨២ ដែលខ្លួនបានសិក្សានៅចន្លោះឆ្នាំ២០២៤ ដល់ឆ្នាំ២០២៦ ដោយមានអ្នកដែលបានរួចខ្លួនពីទីតាំងប្រព្រឹត្តអំពើឆបោកជាច្រើននាក់ រៀបរាប់ដូចៗគ្នាអំពីចំនួនបុគ្គលិកសន្តិសុខដែលមានចំនួនរាប់សិបនាក់ ហើយជួនកាលមានរហូតដល់រាប់រយនាក់ **ដែលសន្តិសុខទាំងនោះមានតួនាទីឃុំឃាំងមនុស្ស រារាំងការរត់គេចខ្លួន ដាក់ទណ្ឌកម្មអ្នកណាដែលហ៊ានតដៃឬប្រឆាំង ហើយក្នុងករណីជាច្រើនបានចូលរួមដោយផ្ទាល់នៅក្នុងការធ្វើទារុណកម្ម និងការរំលោភបំពានធ្ងន់ធ្ងរផ្សេងៗទៀតផងដែរ។**

អង្គការលើកលែងទោសអន្តរជាតិបានកំណត់អត្តសញ្ញាណក្រុមហ៊ុនសន្តិសុខយ៉ាងតិចចំនួនប្រាំគឺ៖

ក្រុមហ៊ុនសន្តិសុខ លាភសំណាង ស៊ីឃ្យួរីធី ឯ.ក

ក្រុមហ៊ុនសន្តិសុខ ស៊ីឃ្យូរីធី វីស្ស៊ន (ខេមបូឌា) ឯ.ក

ក្រុមហ៊ុនសន្តិសុខ ហ្សេតឌី ស៊ីឃ្យូរីធី ឯ.ក

ក្រុមហ៊ុនសន្តិសុខ តារា ស៊ីឃ្យូរីធី សឺវីស ឯ.ក

ក្រុមហ៊ុនសន្តិសុខ បេស (ខេមបូឌា) ស៊ីឃ្យូរីធី សឺវីស ឯ.ក

ដែលក្រុមហ៊ុនទាំងនេះកំពុងផ្តល់សេវាកម្មសន្តិសុខដល់ទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងហោចណាស់ ២៣ទីតាំង។

អង្គការលើកលែងទោសអន្តរជាតិ ក៏បានរកឃើញទំនាក់ទំនងរវាងសមាជិកដែលកំពុងបម្រើការងារនៅក្នុងកងយោធពលខេមរភូមិន្ទ(RCAF) និងនគរបាលជាតិកម្ពុជា ជាមួយទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងហោចណាស់ ២២កន្លែង ក្នុងចំណោមទីតាំងសរុបចំនួន ៨៦ ដែលមានទីតាំងនៅក្នុងខេត្តចំនួន ១០។

អង្គការលើកលែងទោសអន្តរជាតិអំពាវនាវឱ្យមានការស៊ើបអង្កេតលើក្រុមហ៊ុនសន្តិសុខទាំងនេះ រួមទាំងម្ចាស់ នាយក និងអ្នកគ្រប់គ្រង ព្រមទាំងបុគ្គលិកសន្តិសុខមួយចំនួន (ប្រសិនបើពាក់ព័ន្ធ) និងតួអង្គផ្សេងទៀត ដូចជាបុគ្គលមកពីជួរយោធា ប៉ូលិស អ្នកដែលមានទំនាក់ទំនងនយោបាយ ចំពោះការរួមចំណែករបស់ពួកគេក្នុងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មផ្សេងទៀតនៅក្រោមច្បាប់ជាតិ និងអន្តរជាតិ ។

1.1 វិធីសាស្រ្ត

ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ អង្គការលើកលែងទោសអន្តរជាតិបានធ្វើការស៊ើបអង្កេតលើឧស្សាហកម្មឆបោកនៅកម្ពុជា ហើយកំណត់បាននូវទីតាំងប្រព្រឹត្តអំពើឆបោកចំនួន ៨៦ ទីតាំងនៅទូទាំងប្រទេស ដោយសម្ភាសអ្នកដែលបានរួចខ្លួនពីទីតាំងប្រព្រឹត្តអំពើឆបោកទាំងនោះជាង ១៥០នាក់ និងពិនិត្យមើលកំណត់ត្រាជនរងគ្រោះបន្ថែមជាង ៤០០នាក់។ ការស្រាវជ្រាវនោះបាននាំឱ្យមានការចេញផ្សាយរបាយការណ៍ចំនួន២គឺ៖ "ខ្ញុំគឺជាទ្រព្យសម្បត្តិរបស់អ្នកដទៃ"៖ ទាសភាព ការជួញដូរមនុស្ស និងការធ្វើទារុណកម្មនៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោកនៅកម្ពុជា (ខែមិថុនា ឆ្នាំ២០២៥) និងបរាជ័យក្នុងការបង្ក្រាប៖ បរាជ័យនៃ "ការបង្ក្រាប" លើទីតាំងប្រព្រឹត្តអំពើឆបោក និងការជួយដល់ជនរងគ្រោះ របស់កម្ពុជា (ខែមិថុនា ឆ្នាំ២០២៦) ។

របាយការណ៍បច្ចុប្បន្ននេះពិនិត្យទៅលើតួអង្គ ឬក្រុមអ្នករួមចំណែកសំខាន់មួយក្រុម ក្នុងការប្រព្រឹត្តការរំលោភសិទ្ធិមនុស្សនៅទីតាំងប្រព្រឹត្តអំពើឆបោក៖ ក្រុមនោះគឺក្រុមហ៊ុនសន្តិសុខឯកជនដែលការពារនៅទីតាំងប្រព្រឹត្តអំពើឆបោក។ ឯកសារនេះធ្វើកំណត់ត្រាភស្តុតាង កំណត់អត្តសញ្ញាណ**ក្រុមហ៊ុនសន្តិសុខយ៉ាងតិចចំនួន៥ ដែលផ្តល់សេវាសន្តិសុខដល់ទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងតិចចំនួន ២៣កន្លែង** ចាប់ពីដើមខែធ្នូ ឆ្នាំ២០២១ ដល់ខែមិថុនា ឆ្នាំ២០២៦ ដែលទីតាំងប្រព្រឹត្តអំពើឆបោកទាំងនោះមាននៅពាសពេញប្រទេស រួមមានក្នុងខេត្ត ព្រះសីហនុ កោះកុង បន្ទាយមានជ័យ ស្វាយរៀង កំពត ត្បូងឃ្មុំ មណ្ឌលគិរី ព្រៃវែង តាកែវ និងព្រះវិហារ។ របាយការណ៍នេះក៏បានពិនិត្យមើលទៅលើ**ទំនាក់ទំនងរវាងក្រុមហ៊ុនសន្តិសុខទាំងនេះ ជាមួយមន្ត្រីប៉ូលីស និងយោធាផងដែរ។**

ដើម្បីកំណត់អត្តសញ្ញាណក្រុមហ៊ុនសន្តិសុខដែលកំពុងប្រតិបត្តិការនៅទីតាំងប្រព្រឹត្តអំពើឆបោក អង្គការលើកលែងទោសអន្តរជាតិបានពឹងផ្អែកលើប្រភពព័ត៌មានដូចខាងក្រោម៖

- **ការចុះទៅពិនិត្យទីតាំងជាក់ស្តែងចំនួន៨២ នៃទីតាំងប្រព្រឹត្តអំពើឆបោកទាំង៨៦ទីតាំង** ដែលបានកំណត់នៅក្នុងរបាយការណ៍ឆ្នាំ២០២៥ និងរបាយការណ៍ខែមិថុនា ឆ្នាំ២០២៦ របស់ខ្លួន។ ក្នុងអំឡុងពេលចុះពិនិត្យទាំងនេះ ក្រុមអ្នក

ស្រាវជ្រាវបានថតរូបអ្នកការពារសន្តិសុខ ដែលអនុញ្ញាតឱ្យពួកគេកំណត់ស្លាកសញ្ញា និងឯកសណ្ឋានរបស់ក្រុមហ៊ុន និងបង្ហាញរូបថតទៅកាន់អ្នកដែលបានរួចខ្លួនពីទីតាំងប្រព្រឹត្តអំពើឆបោកទាំងនោះ។

- **ការសម្ភាសជាមួយអ្នកដែលបានរួចខ្លួនចំនួន ១៥១នាក់** មកពីទីតាំងប្រព្រឹត្តអំពើឆបោក ដែលបានធ្វើឡើងនៅចន្លោះខែមករា ឆ្នាំ២០២៣ ដល់ខែកញ្ញា ឆ្នាំ២០២៦ ដែលពួកគេភាគច្រើនបានធ្វើការចំណាំស្លាកសញ្ញារបស់ក្រុមហ៊ុនសន្តិសុខ និងបានពិពណ៌នាអំពីការរំលោភបំពានដែលធ្វើឡើងដោយក្រុមសន្តិសុខ។

- **កំណត់ទីតាំងភូមិសាស្ត្រនៃវីដេអូដែលបានបង្ហោះដោយគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមចំនួន ២២២ ដែលត្រូវបានបញ្ជាក់ថាជាកម្មសិទ្ធិរបស់អ្នកយាម ឬបង្ហាញពីសន្តិសុខកំពុងធ្វើការការពារនៅទីតាំងប្រព្រឹត្តអំពើឆបោក។** អង្គការលើកលែងទោសអន្តរជាតិបានពិនិត្យវីដេអូ និងរូបភាពជាង ២៥,០០០ ពីគណនីទាំងនេះនៅចន្លោះខែមិថុនា និងខែសីហា ឆ្នាំ២០២៦។

- ពិនិត្យព័ត៌មាន និង**ឯកសារដែលបោះផ្សាយដោយក្រុមហ៊ុន ឬបុគ្គលិករបស់ពួកគេ** រួមទាំងឯកសារសាជីវកម្មដែលបានដាក់ជូនក្រសួងពាណិជ្ជកម្ម។ ការផ្សាយពាណិជ្ជកម្មការងារដែលបានបង្ហោះនៅលើទំព័រក្រុមហ៊ុនតាមរយៈ Telegram, Facebook និង TikTok ចន្លោះខែមករា ឆ្នាំ២០២៥ និងខែសីហា ឆ្នាំ២០២៦ និងព័ត៌មានផ្សេងទៀតដែលបានបង្ហោះនៅលើគេហទំព័ររបស់ក្រុមហ៊ុន ឬប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ពួកគេ។

- ការវិភាគរូបថត និងវីដេអូដែលបានមកពីទីតាំងប្រព្រឹត្តអំពើឆបោក ដើម្បីវាយតម្លៃថាតើបុគ្គលដែលបានបង្ហាញ **ជាអតីតសមាជិកនៃកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ ឬបច្ចុប្បន្នជាសមាជិកកំពុងបំរើការនៅកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ ដោយផ្អែកលើឯកសណ្ឋាន គ្រឿងឥស្សរិយយស ចំណាត់ថ្នាក់(ស័ក្ក)** និងសូចនាករកំណត់អត្តសញ្ញាណផ្សេងទៀត។

- **ការវិភាគរូបភាពតាមផ្កាយរណប ដើម្បីកំណត់ទីតាំងយាមជាក់លាក់** និងប៉មហេដ្ឋារចនាសម្ព័ន្ធសន្តិសុខផ្សេងទៀតនៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោក។ ។

- **ប្រភព និងឯកសារបន្ទាប់បន្សំ**ជាច្រើនទៀត រួមទាំងរបាយការណ៍ដែលចេញផ្សាយដោយអង្គការសហប្រជាជាតិ និងអង្គការសង្គមស៊ីវិល របាយការណ៍បានមកពីប្រព័ន្ធផ្សព្វផ្សាយ ការកំណត់ការដាក់ទណ្ឌកម្ម និងឯកសារពាក់ព័ន្ធផ្សេងទៀត។

ឧបសម្ព័ន្ធ១ នៃរបាយការណ៍នេះគូសបញ្ជាក់ព័ត៌មានលម្អិតសំខាន់ៗអំពីទីតាំងប្រព្រឹត្តអំពើឆបោកចំនួន ២៣ទីតាំង ភ្ជាប់ទៅក្រុមហ៊ុនសន្តិសុខមួយដែលគេស្គាល់។

ឧបសម្ព័ន្ធ២ នៃរបាយការណ៍នេះកំណត់នូវភស្តុតាងភ្ជាប់គណនីប្រព័ន្ធផ្សព្វផ្សាយសង្គមចំនួន១៩ ដែលបញ្ជាក់អំពីវត្តមាន ឬសកម្មភាពនៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោក ទៅនឹងបុគ្គលដែលមើលទៅដូចជាសមាជិកសកម្មនៃកងយោធពលខេមរភូមិន្ទ(RCAF) និងប៉ូលីស។

អង្គការលើកលែងទោសអន្តរជាតិ បានសរសេរលិខិតទៅកាន់រដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុននានា និងបុគ្គលដែលមានឈ្មោះក្នុងរបាយការណ៍នេះ ដើម្បីផ្តល់ឱកាសឱ្យពួកគេធ្វើការឆ្លើយតបទៅនឹងការរកឃើញរបស់អង្គការ។ **ឧបសម្ព័ន្ធ៣** រួមមានការឆ្លើយតបរបស់រដ្ឋាភិបាល ក្រុមហ៊ុន និងបុគ្គលនានា ដែលបានឆ្លើយតបទៅនឹងលិខិតទំនាក់ទំនងរបស់អង្គការលើកលែងទោសអន្តរជាតិ។

1.2 សារតា

ចាប់តាំងពីមានជំងឺរាតត្បាតកូវីដ-១៩មក ប្រទេសកម្ពុជាបានក្លាយជាមជ្ឈមណ្ឌលពិភពលោកដ៏សំខាន់មួយសម្រាប់ឧស្សាហកម្មឆបោកតាមអ៊ីនធឺណិត ដែលវិវត្តពីការលេងល្បែងស៊ីសងខុសច្បាប់ និងប្រតិបត្តិការក្លែងបន្លំទៅជាប្រព័ន្ធឧក្រិដ្ឋកម្មឆ្លងដែនដែលមានការរៀបចំខ្ពស់។ ប្រតិបត្តិការដែលមានតម្លៃរាប់ពាន់លានដុល្លារទាំងនេះពឹងផ្អែកយ៉ាងខ្លាំងលើពលករដែលត្រូវបានគេជួញដូរមកពីជុំវិញពិភពលោក ដែលភាគច្រើនត្រូវបានទាក់ទាញ ឬបោកឱ្យមកប្រទេសកម្ពុជាតាមរយៈការផ្សព្វផ្សាយព័ត៌មានការងារក្លែងក្លាយ ហើយបន្ទាប់មកទទួលរងនូវការបង្ខិតបង្ខំ អំពើហិង្សា និងការកេងប្រវ័ញ្ច។ ការរំលោភបំពានទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយក្រុមឧក្រិដ្ឋជនអន្តរជាតិ ដែលរៀបចំប្រតិបត្តិការឆ្លងព្រំដែន និងបានជ្រើសរើសជនរងគ្រោះមកពីរាប់សិបប្រទេស។ ទោះបីជាសកម្មភាពបោកបន្លំជាឧក្រិដ្ឋកម្មក៏ដោយ តែវាត្រូវបានបង្កប់នៅក្នុងរចនាសម្ព័ន្ធអាជីវកម្មដែលមើលទៅហាក់ដូចជាស្របច្បាប់ រួមទាំងកាស៊ីណូ និងសណ្ឋាគារដែលមានអាជ្ញាប័ណ្ណដែលប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស និងតាមរយៈក្រុមហ៊ុនដែលបានចុះបញ្ជី រួមទាំងក្រុមហ៊ុនសន្តិសុខផងដែរ។

ដើម្បីឆ្លើយតបទៅនឹងសម្ពាធអន្តរជាតិដែលកំពុងកើនឡើង រដ្ឋាភិបាលកម្ពុជាបានបើកការបង្ក្រាបទូទាំងប្រទេសលើទីតាំងប្រព្រឹត្តអំពើឆបោកជាច្រើនកន្លែង នៅក្នុងខែកក្កដា ឆ្នាំ២០២៥ ដោយរាយការណ៍ពីការអន្តរាគមន៍រាប់រយលើក ដែលក្នុងនោះរួមមានការចាប់ខ្លួន និងជួយសង្គ្រោះផងដែរ។ ខណៈដែលអាជ្ញាធរអះអាងថាបានរុះរើមជ្ឈមណ្ឌលឆបោករាប់រយកន្លែង និរទេសជនបរទេសរាប់ពាន់នាក់ និងលុបបំបាត់ប្រតិបត្តិការឆបោកទ្រង់ទ្រាយធំ អង្គការលើកលែងទោសអន្តរជាតិបានកំណត់ចំណុចខ្វះខាតសំខាន់ៗក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ រួមទាំងការបរាជ័យក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរ និងការផ្តន្ទាទោសជនល្មើស បើទោះបីជាមានភស្តុតាងភ្ជាប់កាស៊ីណូដែលមានអាជ្ញាប័ណ្ណជាច្រើន និងអ្នកជំនួញដែលលេចធ្លោមួយចំនួនទៅនឹងទីតាំងប្រព្រឹត្តអំពើឆបោកក៏ដោយ។ ជាលទ្ធផល ការព្រួយបារម្ភនៅតែបន្តកើតមាន ថាបណ្តាញប្រព្រឹត្តអំពើឆបោកបានបង្កប់ខ្លួនយ៉ាងជ្រៅនៅក្នុងប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចរបស់កម្ពុជា។

បើទោះបីជាមានការរាយការណ៍ជាសាធារណៈជាច្រើនឆ្នាំ និងប្រតិបត្តិការអនុវត្តច្បាប់ដដែលៗក៏ដោយ ការរំលោភសិទ្ធិមនុស្សនៅតែបន្តកើតមានក្នុងទីតាំងប្រព្រឹត្តអំពើឆបោកនៅប្រទេសកម្ពុជា ដោយសារតែតួនាទីរបស់បុគ្គលជាសន្តិសុខដែលគ្រប់គ្រងការចូលទៅកាន់ទីតាំងប្រព្រឹត្តអំពើឆបោក រារាំងការរត់គេចខ្លួន និងអនុវត្តការបង្ខិតបង្ខំជាប្រព័ន្ធនៅខាងក្នុង។

1.3 តួនាទីរបស់បុគ្គលិកសន្តិសុខ

> **“ពួកគេមិនត្រូវការបន្លាលួសទេ [...] មានសន្តិសុខច្រើនណាស់”។**

បុគ្គលិកសន្តិសុខដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ខាំងមនុស្ស ការឃ្លាំមើល ការបង្ខិតបង្ខំ និងការដាក់ទណ្ឌកម្មដែលត្រូវបានប្រើដើម្បីដកហូតសេរីភាពពីជនរងគ្រោះនៃការជួញដូរមនុស្ស និងគ្រប់គ្រងពលកម្មដោយបង្ខំ ការធ្វើទារុណកម្ម ការចាប់រំលោភសេពសន្ថវៈ និងក្នុងករណីជាច្រើន ការធ្វើទាសភាព។ ទីតាំងប្រព្រឹត្តអំពើឆបោកទាំង៨២ ដែលអង្គការលើកលែងទោសអន្តរជាតិបានទៅដល់ ក្នុងឆ្នាំ២០២៤ ២០២៥ និង ២០២៦ បានប្រើប្រាស់បុគ្គលិកសន្តិសុខ ខណៈដែលសក្ខីកម្មពីអ្នកដែលបានរួចខ្លួន ខ្លឹមសារប្រព័ន្ធផ្សព្វផ្សាយសង្គម និងរូបភាពផ្កាយរណបបង្ហាញថា ទីតាំងប្រព្រឹត្តអំពើឆបោកជាច្រើនមានបុគ្គលិកសន្តិសុខរាប់សិបនាក់ និងពេលខ្លះមានដល់រាប់រយនាក់។

ទុកមនុស្សនៅខាងក្នុង

សក្ខីកម្មរបស់អ្នកដែលបានរួចខ្លួនបង្ហាញថា បុគ្គលិកសន្តិសុខជាអ្នកគ្រប់គ្រងការចូលទៅកាន់ទីតាំងប្រព្រឹត្តអំពើឆបោក ត្រួតពិនិត្យយានយន្ត និងភ្ញៀវ តាមដានសកម្មភាព ឬការផ្លាស់ទីរបស់ពលករ នាំមនុស្សទៅនិងមកនៅក្នុងទីតាំង និងឆ្លើយតបនឹងការប៉ុនប៉ងរត់គេច។ អ្នកដែលបានរួចខ្លួនជាច្រើននាក់បានរាយការណ៍ថាជាសាក្សី ឬមានបទពិសោធន៍បានឃើញសន្តិសុខវាយមនុស្សដែលព្យាយាមរត់គេចខ្លួន។

ផលវិបាកសម្រាប់ការប៉ុនប៉ងរត់គេចខ្លួនអាចនឹងធ្ងន់ធ្ងរ។ នៅឯ PO21 ដែលជាទីតាំងប្រព្រឹត្តអំពើឆបោកមួយក្នុងក្រុងប៉ោយប៉ែត ហៅថា “ច្រកខ្មៅ-Blackgate” កុមារដែលបានរួចខ្លួនម្នាក់មកពីប្រទេសថៃបាននិយាយថា សន្តិសុខម្នាក់បានវាយគាត់យ៉ាងធ្ងន់ធ្ងររហូតដល់គាត់មិនអាចអង្គុយបាន។ អ្នកដែលបានរួចខ្លួន ពីការព្យាយាមរត់គេចខ្លួនយ៉ាងច្រើននៅក្នុងខែកក្កដា ឆ្នាំ២០២៥ បានរាយការណ៍ថាសន្តិសុខចាប់បានអ្នកដែលរត់គេចខ្លួនជាច្រើននាក់ទៅវិញ។

អំពើហឹង្សា ការធ្វើទារុណកម្ម និងការរំលោភបំពានផ្សេងទៀត

បុគ្គលិកសន្តិសុខមិនគ្រាន់តែអនុវត្តការបង្ខាំងមនុស្សប៉ុណ្ណោះទេ។ អ្នកដែលបានរួចខ្លួនមួយចំនួនបានរៀបរាប់ថា សន្តិសុខទាំងនោះជាអ្នក**ចូលរួមយ៉ាងសកម្មនៅក្នុងប្រព័ន្ធនៃការធ្វើទារុណកម្ម ការរំលោភបំពានផ្លូវភេទ និងការរំលោភបំពានផ្សេងទៀត**។ អ្នកដែលបានរួចខ្លួន បានរាយការណ៍ថា អំពើហឹង្សាត្រូវបានប្រើប្រាស់ជាទូទៅដើម្បីដាក់ទណ្ឌកម្មអ្នកដែលប៉ុនប៉ងរត់គេចខ្លួន ប្រឆាំងនឹងបញ្ជា ឬមិនបានបំពេញតាមគោលដៅការងារ។ *Gabe* (មិនមែនឈ្មោះពិតរបស់គាត់) ជាបុរសជនជាតិអ៊ូហ្គង់ដាបាននិយាយថាគាត់ត្រូវបានគេធ្វើទារុណកម្មនៅ PV01 (Park 8) ដោយសន្តិសុខដែលពាក់ឯកសណ្ឋានខុសប្លែកពីក្រុមសន្តិសុខដែលយាមនៅបរិវេណខាងក្រៅ។ Gabe បាននិយាយថា គាត់ត្រូវបានគេនាំទៅបន្ទប់ងងឹតមួយដែលមានអាងទឹកធំ។

> **“ពួកគេបង្ខំឱ្យខ្ញុំឈរនៅក្នុងទឹក ដោយឱ្យខ្ញុំស្លៀកតែខោក្នុងជាច្រើនម៉ោង។ ពេលខ្លះពួកគេបានដាក់ច្រវាក់ដៃហើយព្យួរខ្ញុំទៅនឹងបង្គោលលើទឹក។ ពេលខ្លះពួកគេបានចូលមក ហើយគ្រាន់តែវាយខ្ញុំហើយវាយទៀតជាច្រើនម៉ោងមិនឈប់ […] ពួកគេឆក់ខ្ញុំដោយដំបងឆក់ ខណៈខ្ញុំកំពុងនៅក្នុងទឹកនៅឡើយ”**

Kenyangi (មិនមែនឈ្មោះពិតរបស់នាង) ជាស្ត្រីជនជាតិអ៊ូហ្គង់ដាម្នាក់បាននិយាយថា បុគ្គលិកសន្តិសុខនៅឈរក្បែរនោះខណៈដែលចៅកែនាងរំលោភនាងម្តងហើយម្តងទៀត។ អ្នកដែលបានរួចខ្លួនជាច្រើននាក់បានរាយការណ៍ថា បុគ្គលិកសន្តិសុខជាអ្នកធ្វើទារុណកម្ម និងការរំលោភបំពានផ្សេងទៀតដោយផ្ទាល់ រួមទាំងការវាយដំ ការប្រើអគ្គិសនីឆក់ ការដាក់ឱ្យនៅតែឯង និងការឃុំខ្លួនយូរនៅក្នុង “បន្ទប់ងងឹត”។ *Kane* (មិនមែនឈ្មោះពិត) ជាជនជាតិកេនយ៉ា បានរៀបរាប់ថាត្រូវបានគេឃុំខ្លួនក្នុងទ្រុង ដែលសន្តិសុខកាន់ដំបងឆក់ និងដំបងដែកចូលជាប្រចាំ ដើម្បីវាយអ្នកជាប់ឃុំតាមការបញ្ជារបស់អ្នកគ្រប់គ្រងទីតាំង។ នៅក្នុងទីតាំងមួយ Park 8 អ្នកដែលបានរួចខ្លួនបានរាយការណ៍ថា បុគ្គលិកសន្តិសុខឈរនៅខាងក្រៅបន្ទប់ខណៈពេលដែលស្ត្រីត្រូវបានចាប់រំលោភដោយអ្នកគ្រប់គ្រង ហើយបុគ្គលិកសន្តិសុខក៏មានតួនាទីនាំស្ត្រីដែលត្រូវបានរំលោភទៅជួបពេទ្យក្នុងករណីមានផ្ទៃពោះ។

ការកាន់កាប់អាវុធ

សក្ខីកម្មអ្នកដែលបានរួចខ្លួន ភស្តុតាងពីប្រព័ន្ធផ្សព្វផ្សាយសង្គម និងការស៊ើបអង្កេតពីមុនរបស់អង្គការលើកលែងទោសអន្តរជាតិបង្ហាញថា **បុគ្គលិកសន្តិសុខនៅឯទីតាំងប្រព្រឹត្តអំពើឆបោកតែងតែមានកាន់កាប់ និងប្រើប្រាស់អាវុធ**។ ភាគច្រើននៃអ្នកដែលបានរួចខ្លួនចំនួន១៥១នាក់ ដែលត្រូវបានសម្ភាសដោយអង្គការលើកលែងទោសអន្តរជាតិបានរាយការណ៍ថាបានឃើញសន្តិសុខកាន់ ឬមានដំបងឆក់ ដែលអ្នកដែលបានរួចខ្លួនទាំងនោះពិពណ៌នាថាជាឧបករណ៍ប្រើសម្រាប់បំភិតបំភ័យ ធ្វើបាប និងដាក់ទណ្ឌកម្ម។ អ្នកដែលបានរួចខ្លួនម្នាក់ពីទីតាំង P018 ចាប់ផ្តើមយំនៅពេលនាងនឹកឃើញពីសំឡេងដំបងឆក់។

Pattara (មិនមែនឈ្មោះពិតរបស់នាង) បាននិយាយថា សន្តិសុខចូលក្នុងបន្ទប់ជាប្រចាំដោយមានកាន់ដំបងឆក់ត្រៀមជាស្រេច ដើម្បីជួយទប់ស្កាត់កុំឱ្យមានការតតាំងដែលអាចកើតមាននៅពេលដែលពួកគេធ្វើការឆែកឆេរកាបូប និងសាកសួរជនរងគ្រោះ។ នាងបាននិយាយថាក្មេងៗនៅក្នុងបន្ទប់យំក្នុងអំឡុងពេលនោះ។

ជាងមួយភាគបីនៃអ្នកដែលបានរួចខ្លួនចំនួន១៥១នាក់ ដែលត្រូវបានសម្ភាសន៍រាយការណ៍ថា បានឃើញសន្តិសុខ ឬមនុស្សផ្សេងទៀតកាន់អាវុធ រួមទាំងកាំភ្លើងខ្លី និងកាំភ្លើងវែង។ អ្នកដែលបានរួចខ្លួនបានរាយការណ៍ថាបានឃើញអាវុធនៅទីតាំងប្រព្រឹត្តអំពើឆបោកជិត២០ទីតាំងផ្សេងៗគ្នា រួមទាំងនៅកន្លែងដែលត្រូវបានការពារដោយក្រុមហ៊ុនសន្តិសុខដែលត្រូវបានពិនិត្យឬកត់ត្រានៅក្នុងរបាយការណ៍នេះ។ នៅ Park 8 អ្នកដែលបានរួចខ្លួនជាច្រើនបាននិយាយថា សន្តិសុខម្នាក់បានបាញ់ទៅលើអាកាស បន្ទាប់ពីកម្មករទាមទារយកលិខិតឆ្លងដែនរបស់ពួកគេមកវិញ។ អ្នកដែលបានរួចខ្លួន បានរាយការណ៍បន្ថែមថាសន្តិសុខបានប្រើសត្វឆ្កែធំៗជាផ្នែកមួយនៃប្រតិបត្តិការសន្តិសុខក្នុងទីតាំង រួមទាំងប្រើសត្វឆ្កែដើម្បីល្បាតនៅតាមជញ្ជាំង និងយ៉ាងហោចណាស់មានមួយករណី ដែលគេប្រើសត្វឆ្កែដើម្បីដេញតាមមនុស្សដែលប៉ុនប៉ងរត់គេច។

1.4 ការធានាប្រាក់ចំណេញ

ថ្វីត្បិតតែបុគ្គលិកសន្តិសុខជាស្នូលនៃប្រតិបត្តិការនៃទីតាំងប្រព្រឹត្តអំពើឆបោកក៏ដោយ ក៏ពួកគេបានដឹងតិចតួចប៉ុណ្ណោះអំពីក្រុមហ៊ុនដែលបានជួល និងដាក់ពង្រាយពួកគេ។ របាយការណ៍នេះបង្ហាញពីក្រុមហ៊ុនចំនួន៥ ដែលមានទំនាក់ទំនងជាមួយនឹងទីតាំងប្រព្រឹត្តអំពើឆបោកដ៏ធំបំផុតមួយចំនួនរបស់ប្រទេស។ ក្រុមហ៊ុនទាំងនេះមិនមែនជាអង្គភាពអាជីវកម្មដាច់ដោយឡែកនោះទេ ប៉ុន្តែពួកវាស្ថិតនៅក្នុងបណ្តាញមួយដែលភ្ជាប់អ្នកផ្តល់សេវាសន្តិសុខឯកជន ទៅនឹងបុគ្គលិកយោធា មន្ត្រីប៉ូលិស បុគ្គលដែលមានឥទ្ធិពលនយោបាយ (PEPs) និងក្រុមអាជីវកម្មដែលមានអំណាច។ បណ្តាញទាំងនេះបង្កើតបានជាផ្នែកមួយនៃរចនាសម្ព័ន្ធដែលអនុញ្ញាតឱ្យឧស្សាហកម្មឆបោកនេះអាចដំណើរការទៅបាន។ សក្ខីកម្មរបស់អ្នកដែលបានរួចខ្លួន បង្ហាញថាសន្តិសុខដែលជួលដោយក្រុមហ៊ុនទាំងនេះមិនគ្រាន់តែទទួលខុសត្រូវចំពោះសន្តិសុខនៅទីតាំងប្រព្រឹត្តអំពើឆបោកនោះទេ ប៉ុន្តែក្នុងករណីជាច្រើនបានចូលរួមដោយផ្ទាល់នៅក្នុងប្រព័ន្ធនៃការបង្ខាំង ការបង្ខិតបង្ខំ និងអំពើហិង្សាដែលទ្រទ្រង់ឧស្សាហកម្មឆបោក។

- **ក្រុមហ៊ុនសន្តិសុខ លាភសំណាង ស៊ីឃ្យូរីធី ឯ.ក បានផ្តល់សេវាសន្តិសុខដល់ទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងហោចណាស់ ១៥ទីតាំង ដែលធ្វើឱ្យក្រុមហ៊ុននេះក្លាយជាអ្នកផ្តល់សេវាសន្តិសុខដែលត្រូវបានកំណត់អត្តសញ្ញាណញឹកញាប់បំផុត នៅក្នុងរបាយការណ៍នេះ។** លោក បាន សុផាត ត្រូវបានគេជឿថាជាអ្នកគ្រប់គ្រងក្រុមហ៊ុន លាភ សំណាង ហើយបានបង្ហាញខ្លួនជាសាធារណៈក្នុងនាមជាប្រធានក្រុមហ៊ុន ខណៈដែលលោកក៏មានឋានៈជាវរសេនីយ៍ឯកនៅក្នុងកងយោធពលខេមរភូមិន្ទ (RCAF) ផងដែរ។ ក្រុមហ៊ុននេះមានទំនាក់ទំនងទៅនឹងបុគ្គលលេចធ្លោមួយចំនួននៅក្នុងឧស្សាហកម្មឆបោក រួមទាំងអ្នកឧកញ៉ា លី គួង ដែលត្រូវបានចាប់ខ្លួនក្នុងឆ្នាំ២០២៦ ក្រោមការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មមានអង្គការចាត់តាំង ការលាងលុយកខ្វក់ និងការជ្រើសរើសមនុស្សមកដើម្បីធ្វើការកេងប្រវ័ញ្ចដោយខុសច្បាប់។ អ្នកដែលបានរួចខ្លួន បានរាយការណ៍ជាញឹកញាប់ថាសន្តិសុខរបស់ក្រុមហ៊ុន លាភសំណាង ដែលពួកគេបានកំណត់អត្តសញ្ញាណដោយស្លាកសញ្ញារបស់ក្រុមហ៊ុន ជាអ្នកបំបិទសេរីភាពរបស់ពួកគេក្រោមការគំរាមកំហែងដោយអំពើហិង្សា ហើយក្នុងករណីខ្លះបានចូលរួមដោយផ្ទាល់នៅក្នុងការធ្វើទារុណកម្ម និងការរំលោភបំពានផ្សេងទៀត រួមទាំងការវាយដំ ការឆក់ខ្សែភ្លើង ការឃុំខ្លួនដាច់ដោយឡែកតែឯងក្នុងរយៈពេលយូរ និងការគំរាមសម្លាប់។ អ្នកដែលបានរួចខ្លួនម្នាក់បាននិយាយថា សន្តិសុខម្នាក់បានដាល់គាត់យ៉ាងធ្ងន់ធ្ងរ រហូតដល់បាក់ធ្មេញជាច្រើន ខណៈជនរងគ្រោះម្នាក់ទៀតបានរាយការណ៍ថាក្រុមសន្តិសុខបានវាយបំបាក់ជើងមិត្តភក្តិរបស់គាត់ ដោយសារតែមិត្តភក្តិនោះបានប្រឆាំងតបត។ អ្នកដែលបានរួចខ្លួនម្នាក់ទៀតបានរៀបរាប់ថា ក្រុមសន្តិសុខបានចូលទៅក្នុងបន្ទប់ងងឹតមួយ ហើយប្រើដំបងឆក់អគ្គិសនីវាយឆក់គាត់ តាមការបញ្ជារបស់អ្នកគ្រប់គ្រងទីតាំង។ ភ័ស្តុតាងដែលបានបង្ហាញក្នុងរបាយការណ៍នេះក៏បង្ហាញផងដែរថា សន្តិសុខរបស់ក្រុមហ៊ុន លាភ សំណាង ត្រូវបានដាក់ពង្រាយនៅ

តាមខេត្តជាច្រើន ខណៈពេលដែលពួកគេរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបុគ្គលនៅក្នុងជួរយោធា ប៉ូលិស និងអ្នកពាក់ព័ន្ធនយោបាយមួយចំនួន។

ជាការឆ្លើយតបទៅនឹងការរកឃើញទាំងនេះ លោក បាន សុផាត បានបដិសេធថាខ្លួនមិនមែនជាម្ចាស់ ថ្នាក់ដឹកនាំ ឬមានតួនាទីគ្រប់គ្រងនៅក្នុងក្រុមហ៊ុនសន្តិសុខ លាភ សំណាង ឬមានជាប់ពាក់ព័ន្ធក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុន ឬការរំលោភបំពានដែលត្រូវបានចោទប្រកាន់ដោយបញ្ជាក់ថាគាត់ "បានបម្រើការជាទីប្រឹក្សាដល់ម្ចាស់ក្រុមហ៊ុន" និង "មិនបានអនុញ្ញាត ដឹកនាំ ឬចូលរួមក្នុងការរំលោភបំពានលើបុគ្គលណាមួយឡើយ" និងបានថ្កោលទោស "ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ ការបង្ខាំងនិងអំពើហឹង្សា" ។

- **ក្រុមហ៊ុនសន្តិសុខ ស៊ីយូរីធី វីស្ស៊ន (ខេមបូឌា) ឯ.ក បានផ្តល់សេវាសន្តិសុខដល់ទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងតិចប្រាំ រួមទាំងទីតាំងប្រព្រឹត្តអំពើឆបោកធំៗមួយចំនួននៅក្នុងប្រទេស។** ភស្តុតាងដែលត្រូវបានពិនិត្យដោយអង្គការលើកលែងទោសអន្តរជាតិបង្ហាញថា ក្រុមហ៊ុនមានទំនាក់ទំនងជិតស្និទ្ធជាមួយធនាគារផេនដា (Panda Bank) និងហួយវ័ន គ្រុប (Huione Group) តាមរយៈការមាននាយករួម និងទំនាក់ទំនងអាជីវកម្ម។ ទំនាក់ទំនងទាំងនេះត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការប្រើប្រាស់អគាររួមគ្នាជាមួយធនាគារផេនដា ដែលបើទោះបីជាការប្រើប្រាស់ការិយាល័យរួមគ្នាមិនមែនជាភស្តុតាងបញ្ជាក់ច្បាស់លាស់ដោយខ្លួនឯងក៏ដោយ ប៉ុន្តែវាក្លាយជាចំណុចដ៏សំខាន់មួយនៅពេលពិចារណារួមគ្នាជាមួយទំនាក់ទំនងផ្សេងៗទៀត។ ទំនាក់ទំនងទាំងនេះមានសារៈសំខាន់ ដោយសារអង្គភាពហួយវ័ន កំពុងប្រឈមមុខនឹងទណ្ឌកម្ម ព្រមទាំងការចោទប្រកាន់ពាក់ព័ន្ធនឹងការលាងលុយកខ្វក់ និងប្រតិបត្តិការឆបោកតាមអ៊ីនធឺណិត។ អ្នកដែលបានរួចខ្លួនបានកំណត់ថាសន្តិសុខរបស់ ស៊ីយូរីធី វីស្ស៊ន ជាអ្នកដែលបានចូលរួមក្នុងការបង្ខាំងមនុស្សដែលត្រូវបានជួញដូរ មានកាន់អាវុធ ការពារការរត់គេចខ្លួន សម្របសម្រួលដល់ការប្រព្រឹត្តហិង្សាផ្លូវភេទ និងចូលរួមដោយផ្ទាល់នៅក្នុងការធ្វើទារុណកម្ម និងការរំលោភបំពានផ្សេងទៀត រួមទាំងការវាយដំ ការឆក់ខ្សែភ្លើង និងការចាប់ចងរយៈពេលយូរ។ ក្រុមហ៊ុននេះហាក់បីដូចជាបានបន្តប្រតិបត្តិការរបស់ខ្លួននៅទីតាំងប្រព្រឹត្តអំពើឆបោកទាំងនេះដដែល បើទោះបីជាមានការអន្តរាគមន៍របស់ប៉ូលីសម្តងហើយម្តងទៀត និងការរាយការណ៍ជាសាធារណៈយ៉ាងទូលំទូលាយក៏ដោយ។ ដោយភ្ជាប់ជាមួយនឹងទំនាក់ទំនងអាជីវកម្មរបស់ខ្លួនជាមួយក្រុមហ៊ុនដែលត្រូវបានចោទប្រកាន់ ឬដាក់ទណ្ឌកម្មពាក់ព័ន្ធនឹងឧស្សាហកម្មឆបោក ក្រុមហ៊ុននេះហាក់ដូចជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ឧស្សាហកម្មឆបោកនេះ។

ជាការឆ្លើយតបទៅនឹងការរកឃើញទាំងនេះ ស៊ីយូរីធី វីស្ស៊ន បានបដិសេធរាល់ការចោទប្រកាន់ទាំងអស់ដោយបញ្ជាក់ថាខ្លួនធ្វើប្រតិបត្តិការស្របច្បាប់ក្នុងនាមជាអ្នកផ្តល់សេវាសន្តិសុខដែលបានចុះបញ្ជី ហើយថាទាំងក្រុមហ៊ុន និងបុគ្គលិករបស់ខ្លួនមិនបានចូលរួម ផ្តល់សិទ្ធិ ឬដឹងអំពីសកម្មភាពខុសច្បាប់ដែលត្រូវបានចោទប្រកាន់នៅទីតាំង ដូចដែលបានលើកឡើងដោយអង្គការលើកលែងទោសអន្តរជាតិទេ។ ខណៈពេលដែលក្រុមហ៊ុនបានបញ្ជាក់ថា "អាសយដ្ឋានចុះបញ្ជីរបស់ក្រុមហ៊ុន" បានផ្លាស់ប្តូរ ក្រុមហ៊ុនមិនបានធ្វើការបដិសេធជាក់លាក់ណាមួយចំពោះទំនាក់ទំនងរបស់ខ្លួនជាមួយធនាគារផេនដា ឬក្រុមហ៊ុនហួយវ័ន គ្រុប នោះទេ។

- **ក្រុមហ៊ុនសន្តិសុខ ហ្សេតឌី ស៊ីយូរីធី ឯ.ក បានផ្តល់សេវាសន្តិសុខដល់ទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងតិចពីរ BS02 និង BS04 នៅបុទុមសាគរ។ BS04** ដែលជារឿយៗត្រូវបានគេហៅយ៉ាងសាមញ្ញថា ឡុង បេ (Long Bay) **គឺជាទីតាំងប្រព្រឹត្តអំពើឆបោកដ៏ល្បីល្បាញបំផុតមួយ ដែលត្រូវបានស៊ើបអង្កេតម្តងហើយម្តងទៀត។** ភស្តុតាងដែលអង្គការលើកលែងទោសអន្តរជាតិ បានពិនិត្យមើលបង្ហាញថា ហ្សេតឌី ស៊ីយូរីធី ដែលពីមុនមានឈ្មោះថាប៊ីក ស៊ីយូរីធី (BIC Security) មានទំនាក់ទំនងជាមួយក្រុមហ៊ុន ហ្សេងហេង គ្រុប (ZhengHeng Group) និងបណ្តាញក្រុមហ៊ុនប៊ីក (BIC) រួមទាំងអាជីវកម្មដែលមានជាប់ពាក់ព័ន្ធជាមួយលោក យឹម លក្ខណ៍ កូនប្រុសរបស់អតីតឧបនាយករដ្ឋមន្ត្រីលោក យឹម ឆៃលី។ អាជ្ញាធរសហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្ម និងស៊ើបអង្កេតបណ្តាញក្រុមហ៊ុនហ្សេងហេង គ្រុប (ZhengHeng Group) ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីសកម្មភាពឧក្រិដ្ឋកម្មនៅតាមទីតាំងប្រព្រឹត្ត

អំពើឆបោក និងការលាងលុយកខ្វក់។ អ្នកដែលបានរួចខ្លួន ដែលត្រូវបានជួញដូរទៅ BS04 បានរៀបរាប់អំពីការធ្វើទារុណកម្ម និងការរំលោភបំពានផ្សេងទៀត ការវាយដំ ការឃុំឃាំងរយៈពេលយូរ និងអំពើហិង្សា បន្ទាប់ពីពួកគេបានលួចស្នើសុំជំនួយពីអាជ្ញាធរកម្ពុជា។ អ្នកដែលបានរួចខ្លួនម្នាក់បានរាយការណ៍ថាត្រូវបានគេនាំទៅក្រៅ ដើម្បីវាយដំ និងចងជាប់នឹងគ្រែអស់រយៈពេលមួយសប្តាហ៍បន្ទាប់ពីគេបដិសេធមិនព្រមធ្វើការ។ អ្នកផ្សេងទៀតបានពណ៌នាថា ក្រុមសន្តិសុខមានកាន់អាវុធ ដែលធ្វើឱ្យការព្យាយាមរត់គេចខ្លួនស្ទើរតែមិនអាចទៅរួច។ វត្តមានរបស់ក្រុមហ៊ុននៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោកដ៏លេចធ្លោមួយ រួមជាមួយនឹងទំនាក់ទំនងរបស់ខ្លួនទៅនឹងអាជីវកម្មដែលមានជាប់ពាក់ព័ន្ធនឹងបុគ្គលនយោបាយ និងតួអង្គដែលមានឥទ្ធិពលទាំងផ្នែកការទូត និងនយោបាយមកពីប្រទេសចិននោះ បានបង្កឱ្យមានក្តីបារម្ភយ៉ាងខ្លាំងអំពីតួនាទីរបស់ក្រុមហ៊ុននេះ ក្នុងការទ្រទ្រង់ឧស្សាហកម្មឆបោកទាំងមូល។

- **ក្រុមហ៊ុនសន្តិសុខ តារា ស៊ីយូរីធី សឺវីស ឯ.ក បានផ្តល់សេវាសន្តិសុខដល់ទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងតិចចំនួនពីរនៅខេត្តព្រះសីហនុ SI03 និង SI50 ដែលអង្គការលើកលែងទោសអន្តរជាតិបានរកឃើញភស្តុតាងអំពីការជួញដូរមនុស្ស ពលកម្មដោយបង្ខំ ការដកហូតសិទ្ធិសេរីភាព និងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរផ្សេងទៀតនៅទីតាំងពីរនេះ។** អ្នកដែលបានរួចខ្លួន បានកំណត់ថាសន្តិសុខក្រុមហ៊ុន តារា ស៊ីយូរីធី ជាអ្នកទទួលខុសត្រូវការពារមនុស្សមិនឱ្យចាកចេញពីទីតាំង ហើយបានរាយការណ៍ថាសន្តិសុខមានកាន់អាវុធ និងដំបងឆក់។ អ្នកដែលបានរួចខ្លួន ពីទីតាំងដែលការពារដោយសន្តិសុខក្រុមហ៊ុន តារា ស៊ីយូរីធី បានរៀបរាប់អំពីទារុណកម្ម និងការរំលោភបំពានផ្សេងទៀត រួមទាំងការវាយដំ ការឆក់ខ្សែភ្លើង និងការគំរាមកំហែងដោយអំពើហិង្សា ខណៈអ្នកដែលបានរួចខ្លួនម្នាក់ បានរាយការណ៍ថាបានឃើញការធ្វើអត្តឃាតរបស់មិត្តរួមការងារដែលត្រូវបានជួញដូរមកទីតាំងនោះដូចគ្នា បន្ទាប់ពីអ្នកដែលបានធ្វើអត្តឃាតនោះទទួលរងការរំលោភបំពាន និងបដិសេធសំណើសុំត្រឡប់ទៅផ្ទះវិញម្តងហើយម្តងទៀត។ អ្នកដែលបានរួចខ្លួនម្នាក់ទៀតមកពី SI50 បានរាយការណ៍ថាបានទទួលរងការឆក់ខ្សែភ្លើងបន្ទាប់ពីគាត់មិនបានបំពេញតាមគោលដៅការងារ។

- **ក្រុមហ៊ុនសន្តិសុខ បេស (ខេមបូឌា) ស៊ីយូរីធី សឺវីស ឯ.ក បានផ្តល់សេវាសន្តិសុខដល់ទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងហោចណាស់មួយ BA06 នៅបាវិត ដែលជាទីតាំងដែលអង្គការលើកលែងទោសអន្តរជាតិកំណត់បានភស្តុតាងអំពីការជួញដូរកុមារ និងការដកហូតសិទ្ធិសេរីភាព។** ទោះបីជាអង្គការលើកលែងទោសអន្តរជាតិបានកំណត់អត្តសញ្ញាណទីតាំងប្រព្រឹត្តអំពើឆបោកតែមួយគត់ដែលមានទំនាក់ទំនងនឹងក្រុមហ៊ុន បេស ស៊ីយូរីធី ក៏ដោយ ប៉ុន្តែទំនាក់ទំនងនេះគឺជារឿងដ៏សំខាន់មួយ។ ភស្តុតាងដែលបានពិនិត្យដោយអង្គការលើកលែងទោសអន្តរជាតិបង្ហាញថាការរំលោភបំពាននានានៅក្នុងទីតាំងBA06 នៅតែបន្តកើតមាន ខណៈពេលដែលក្រុមហ៊ុននេះកំពុងផ្តល់សេវាកម្មសន្តិសុខនៅទីនោះ។ ក្រុមអ្នកស្រាវជ្រាវបានកត់សម្គាល់ឃើញថា មានរបងព័ទ្ធជុំវិញយ៉ាងរឹងមាំ ប៉មយាម និងប៉ុស្តិ៍យាមនៅតាមចំណុចយុទ្ធសាស្ត្រនានា ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្ខាំង និងតាមដានជនរងគ្រោះ។ ទីតាំងនេះក៏ត្រូវបានរកឃើញថាមានទំនាក់ទំនងនឹងអង្គភាពមួយចំនួន ដែលក្រោយមកត្រូវបានដាក់ទណ្ឌកម្មដោយសហរដ្ឋអាមេរិកសម្រាប់ការជាប់ពាក់ព័ន្ធក្នុងប្រតិបត្តិការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត និងពលកម្មដោយបង្ខំ។ លើសពីនេះ នៅខាងក្រៅការិយាល័យរបស់ក្រុមហ៊ុន បេស ស៊ីយូរីធី មានដាក់តាំងស្លាកសញ្ញាមួយដែលមានលេខទូរសព្ទរបស់លោក ឡាយ ចាន់នី (Lay Channy) ដែលជាមន្ត្រីនៃអគ្គស្នងការរងនគរបាលជាតិ។ លោក ឡាយ ចាន់នី គឺជាមន្ត្រីម្នាក់ដែលបានចូលរួមក្នុងប្រតិបត្តិការបង្ក្រាបអំពើឆបោកទូទាំងប្រទេសកម្ពុជា ដែលចំណុចនេះបានបង្កឱ្យមានក្តីបារម្ភអំពីទំនាក់ទំនងរវាងក្រុមហ៊ុនសន្តិសុខនេះ និងអាជ្ញាធរអនុវត្តច្បាប់។

ជាការឆ្លើយតបទៅនឹងការរកឃើញទាំងនេះ ក្រុមហ៊ុន បេស ស៊ីយូរីធី បានបញ្ជាក់ថា ការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនមិនបានរកឃើញកំណត់ត្រាណាមួយដែលបង្ហាញថា ក្រុមហ៊ុនបានផ្តល់សេវាកម្មនៅទីតាំងBA06 នោះទេ។ ក្រុមហ៊ុនបានសន្និដ្ឋានថា ឯកសណ្ឋានសន្តិសុខខ្លួនអាចត្រូវបានគេចម្លង ឬប្រើប្រាស់ខុសដោយភាគីទីបី។ ប្រធានក្រុមហ៊ុនក៏បានបញ្ជាក់ផងដែរថា លោកអនុប្រធានស្នងការនគរបាលរូបនោះ គឺជាម្ចាស់ទីតាំង (ម្ចាស់ដី ឬផ្ទះ) ការិយាល័យសាខាខេត្តស្វាយរៀងដែលក្រុមហ៊ុន

ខ្លួនបានជួល ហើយលេខទូរស័ព្ទរបស់គាត់ត្រូវបានដាក់នៅលើផ្លាកសញ្ញាក្រុមហ៊ុនដើម្បីជួយអតិថិជននៅពេលសាខាត្រូវបានបង្កើតឡើងដំបូង ដោយលោកសង្កត់ធ្ងន់ថា "ប្រតិបត្តិការ ការគ្រប់គ្រងទូទៅ និងការសម្រេចចិត្តទាំងអស់គឺជាការទទួលខុសត្រូវរបស់ភាគីខ្ញុំទាំងស្រុង និងមិនមានពាក់ព័ន្ធនឹងលោក ឡាយ ចាន់នី ឡើយ"។

1.5 ទំនាក់ទំនងកងកម្លាំងយោធា និងមន្ត្រីប៉ូលីស ទៅនឹងទីតាំងប្រព្រឹត្តអំពើឆបោក

អស់រយៈពេលជាច្រើនឆ្នាំមកហើយ អ្នកដែលបានរួចខ្លួនបានរាយការណ៍អំពីវត្តមានរបស់បុគ្គលដែលពួកគេជឿថាជាសមាជិកកងកម្លាំងយោធា ឬមន្ត្រីប៉ូលីសកម្ពុជានៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោក។ ភស្តុតាងបន្ថែមបានបង្ហាញថា អ្នកគ្រប់គ្រងទីតាំងទាំងនោះតែងតែទទួលបានដំណឹងជាមុន មុនពេលដែលប៉ូលិសចុះបង្ក្រាប និងជួយសង្គ្រោះជនរងគ្រោះ។ រហូតមកដល់ពេលនេះ សក្ខីកម្មទាំងនេះមិនអាចផ្ទៀងផ្ទាត់ដោយឯករាជ្យបានទេ។

ភស្តុតាងថ្មីដែលប្រមូលបាន និងផ្ទៀងផ្ទាត់ដោយអង្គការលើកលែងទោសអន្តរជាតិ បានបង្ហាញពីទំនាក់ទំនងផ្ទាល់រវាងមន្ត្រីដែលកំពុងបម្រើការងារនៅក្នុងកងយោធពលខេមរភូមិន្ទ (RCAF) និងកងកម្លាំងនគរបាលជាតិ ជាមួយនឹងទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងហោចណាស់ ២២ ក្នុងចំណោមទីតាំងចំនួន ៨៦ ដែលត្រូវបានកំណត់អត្តសញ្ញាណដោយអង្គការលើកលែងទោសអន្តរជាតិ ដែលទីតាំងទាំងនោះមាននៅក្នុងខេត្តចំនួនដប់ចាប់ពីខែធ្នូ ឆ្នាំ២០២១ ដល់ខែមិថុនា ឆ្នាំ២០២៦។ បុគ្គលទាំងនេះមិនត្រឹមតែដើរតួជាអ្នកយាមកាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើរតួជានាយកក្រុមហ៊ុន ម្ចាស់ផលប្រយោជន៍ អ្នកជ្រើសរើសបុគ្គលិក គ្រូបង្វឹក និងប្រធានក្រុមផងដែរ។ ទោះបីជាភស្តុតាងទាំងនេះមិនអាចបញ្ជាក់បានថា វាគឺជាគោលនយោបាយផ្លូវការរបស់ស្ថាប័នកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក៏ដោយ ប៉ុន្តែការចូលរួមយ៉ាងទូលំទូលាយរបស់មន្ត្រីដែលកំពុងបំពេញការងារទាំងនេះ បង្ហាញយ៉ាងហោចណាស់ថា មានការដឹងឮ និងការយល់ព្រមដោយស្ងៀមស្ងាត់ (ការបណ្តោយឱ្យកើតមាន) ពីសំណាក់បុគ្គលមួយចំនួននៅក្នុងស្ថាប័នទាំងពីរនេះ។

ជាបឋម ភស្តុតាងបានបង្ហាញថាយ៉ាងហោចណាស់មានមន្ត្រីយោធា និងប៉ូលិសជាន់ខ្ពស់បីនាក់ដែលមានជាប់ទាក់ទងទៅនឹងឧស្សាហកម្មឆបោក៖

- **លោកវរសេនីយ៍ឯក បាន សុផាត នៃកងយោធពលខេមរភូមិន្ទ (RCAF)៖** ទោះបីជាលោកបានបដិសេធថាគ្មានការពាក់ព័ន្ធក៏ដោយ អង្គការលើកលែងទោសអន្តរជាតិបានសន្និដ្ឋានថា លោកគឺជាអ្នកដឹកនាំ និងគ្រប់គ្រងក្រុមហ៊ុន «លាភ សំណាង» ដែលបានផ្តល់សេវាកម្មសន្តិសុខដល់ទីតាំងប្រព្រឹត្តអំពើឆបោកយ៉ាងហោចណាស់ ១៥ទីតាំង។
- **លោក ឡាយ ចាន់នី អគ្គស្នងការរងនគរបាលជាតិ៖** យោងតាមក្រុមហ៊ុន បេស ស៊ីយ្យូរីធី លោកគឺជាម្ចាស់អចលនទ្រព្យដែលការិយាល័យសាខារបស់ក្រុមហ៊ុននេះជួល។ ក្រុមហ៊ុនបានបញ្ជាក់ថា លេខទូរសព្ទផ្ទាល់ខ្លួនរបស់លោក (ឡាយ ចាន់នី) ត្រូវបានដាក់បង្ហាញនៅលើស្លាកសញ្ញារបស់ក្រុមហ៊ុន ក្នុងនាមជាលេខទំនាក់ទំនងសម្រាប់អតិថិជន។ ទំនាក់ទំនងរបស់លោក ឡាយ ចាន់នី ជាមួយក្រុមហ៊ុន បេស ស៊ីយ្យូរីធី គឺជារឿងគួរឱ្យកត់សម្គាល់ ដោយសារលោកមានតួនាទីជាក់ស្តែងនៅក្នុងកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ដើម្បីបង្ក្រាបអំពើឆបោកនៅក្នុងខេត្តស្វាយរៀង រួមទាំងការចូលរួមក្នុងប្រតិបត្តិការចុះបង្ក្រាបទីតាំងដែលសង្ស័យថាមានការប្រព្រឹត្តអំពើឆបោក និងការចូលរួមកិច្ចប្រជុំនៅក្រសួងមហាផ្ទៃ ក្នុងនាមជាតំណាងស្នងការនគរបាលខេត្តស្វាយរៀង។
- **លោកឧត្តមសេនីយ៍ទោ តិក ប៊ុនធឿន៖** ក្រុមហ៊ុនរបស់ភរិយាលោក គឺជាអ្នកអភិវឌ្ឍដីដែលទីតាំងប្រព្រឹត្តអំពើឆបោកឈ្មោះ BM02 ស្ថិតនៅ ហើយភស្តុតាងបានបង្ហាញថា លោកបានចូលរួមដោយផ្ទាល់នៅក្នុងគម្រោងអភិវឌ្ឍនេះ។ អង្គការលើកលែងទោសអន្តរជាតិក៏បានរកឃើញភស្តុតាងដែលបង្ហាញថា មានមន្ត្រីយោធាដែលកំពុងបំពេញការងារ

បានចូលរួមក្នុងប្រតិបត្តិការនៅទីតាំងនោះ រួមទាំងការបណ្តុះបណ្តាល និងការត្រួតពិនិត្យកម្លាំងសន្តិសុខ ដោយបុគ្គលម្នាក់ដែលគេសង្ស័យថាជាសមាជិកនៃកងយោធពលខេមរភូមិន្ទ (RCAF)។

អង្គការលើកលែងទោសអន្តរជាតិ បានរកឃើញមានមន្ត្រីកងយោធពលខេមរភូមិន្ទ (RCAF) ឬមន្ត្រីនគរបាលចំនួន ១៩នាក់បន្ថែមទៀត ដែលអ្នកខ្លះមានទំនាក់ទំនងជាមួយក្រុមហ៊ុនសន្តិសុខ លាភ សំណាង អ្នកខ្លះមានទំនាក់ទំនងជាមួយក្រុមហ៊ុនសន្តិសុខ ស៊ីយូរីធី រីស្ស៊ីន និងអ្នកខ្លះទៀតមានទំនាក់ទំនងជាមួយក្រុមហ៊ុនសន្តិសុខ តារា ស៊ីយូរីធី។ ការកំណត់ទីតាំងភូមិសាស្ត្រតាមរយៈរូបភាព បានបង្ហាញថា មន្ត្រីទាំងនេះមានវត្តមាននៅទីតាំងចំនួន ១២កន្លែង (ក្នុងនោះមាន ៦កន្លែង គឺជាទីតាំងដដែលដែលមានជាប់ពាក់ព័ន្ធនឹងលោក បាន សុផាត និងក្រុមហ៊ុនសន្តិសុខ លាភ សំណាង)។ អង្គការលើកលែងទោសអន្តរជាតិបានផ្ទៀងផ្ទាត់រូបភាពឯកសណ្ឋានផ្លូវការដែលពួកគេស្លៀក ជាមួយនឹងសណ្ឋានផ្លូវការដែលមានជាសាធារណៈរបស់មន្ត្រីកងយោធពលខេមរភូមិន្ទ ឬមន្ត្រីនគរបាល ហើយបានរៀបចំជាលំដាប់ពេលវេលា ដែលបង្ហាញថា ពួកគេទំនងជាមន្ត្រីដែលកំពុងបំពេញការងារ ឬជាសមាជិកសកម្មនៃកងកម្លាំងប្រដាប់អាវុធ ខណៈពេលដែលពួកគេកំពុងស្ថិតនៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោកទាំងនោះ។ ក្រៅពីនេះ នៅមានបុគ្គលិកយោធា ឬនគរបាលផ្សេងទៀត ដែលទំនងជាបានចូលទៅក្នុង ឬធ្វើការជាអ្នកយាមនៅតាមទីតាំងប្រព្រឹត្តអំពើឆបោក ប៉ុន្តែពួកគេមិនបានបង្ហាញពីទំនាក់ទំនងរបស់ខ្លួនជាសាធារណៈនៅលើបណ្តាញសង្គមឡើយ។

នៅក្នុងទីតាំងចំនួន ៣កន្លែង **មន្ត្រីយោធាដែលកំពុងបំពេញការងារ បានធ្វើការបណ្តុះបណ្តាល ឬដឹកនាំក្រុមសន្តិសុខ (អ្នកយាម)។** មានគេឃើញបុគ្គលទាំងនេះណែនាំដល់ក្រុមអ្នកយាម ឬទទួលការគោរពតាមបែបយោធាពីសំណាក់អ្នកយាមទាំងនោះ ដោយជាធម្មតាពួកគេឈរនៅពីមុខក្រុមអ្នកយាម ឬសន្តិសុខ។ សកម្មភាពបណ្តុះបណ្តាលទាំងនេះ បានជួយរៀបចំមុខងារ តាមរយៈការផ្ទេរជំនាញ និងការកំណត់ស្តង់ដារប្រតិបត្តិការសម្រាប់កម្លាំងសន្តិសុខ។ ការបណ្តុះបណ្តាលនេះគឺមានភាពចាំបាច់ ដោយសារទីតាំងទាំងនោះតែងតែជួលអ្នកយាមច្រើនជាង១០០នាក់ ហើយអ្នកយាមភាគច្រើនមិនធ្លាប់មានបទពិសោធន៍ធ្វើការផ្នែកសន្តិសុខពីមុនមកឡើយ។

ជាឧទាហរណ៍ អ្នកប្រើប្រាស់ TikTok ម្នាក់ដែលមានឈ្មោះគណនីថា NC001 (ឈ្មោះគណនីត្រូវបានផ្លាស់ប្តូរដើម្បីការពារអត្តសញ្ញាណ) ដូចដែលបានបង្ហាញក្នុងរូបភាពខាងក្រោម គឺជាសមាជិកនៃកងយោធពលខេមរភូមិន្ទ (RCAF) ក្នុងអំឡុងពេលតែមួយដែលគាត់បានបង្ហោះវីដេអូបង្ហាញពីសកម្មភាពរបស់គាត់ក្នុងការដឹកនាំក្រុមសន្តិសុខនៅទីតាំង SI12។ ក្រៅពីនេះ នៅមានអ្នកយាមយ៉ាងហោចណាស់២នាក់ផ្សេងទៀតនៅទីតាំងដដែលនោះ ដែលត្រូវបានបញ្ជាក់ថាជាសមាជិកនៃកងយោធពលខេមរភូមិន្ទ (RCAF) ផងដែរ។

រូបភាពមួយផ្ទាំងពីវីដេអូដែលបានបង្ហោះនៅលើបណ្តាញសង្គម (ខាងឆ្វេង) បង្ហាញពីក្រុមសន្តិសុខឈរតម្រង់ជួរ និងធ្វើការគោរពចំពោះបុរសម្នាក់នៅទីតាំង SI12។ រូបភាពមួយទៀតដែលបានបង្ហោះនៅលើគណនីបណ្តាញសង្គមដដែលនោះ បង្ហាញពីបុរសដដែលនេះកំពុងស្លៀកឯកសណ្ឋានយោធាកម្ពុជា នៅក្នុងពិធីមួយនៅប្រទេសវៀតណាម។ ផ្ទៃមុខត្រូវបានធ្វើឱ្យព្រិលដោយអង្គការលើកលែងទោសអន្តរជាតិ។ ប្រភព៖ អង្គការលើកលែងទោសអន្តរជាតិ អ្នកប្រើប្រាស់ TikTok ឈ្មោះ NC001 (មិនមែនជាឈ្មោះអ្នកប្រើប្រាស់ពិតប្រាកដរបស់គាត់ទេ)។

នៅក្នុងករណីចំនួនបី អង្គការលើកលែងទោសអន្តរជាតិ បានសង្ស័យថាមានសមាជិកនៃកងយោធពលខេមរភូមិន្ទ ឬប៉ូលិស បានកាន់អាវុធដោយបើកចំហ ខណៈពេលដែលពួកគេស្ថិតនៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោក។

រូបភាពមួយផ្ទាំងពីវីដេអូដែលបានបង្ហោះនៅលើបណ្ដាញសង្គម (ខាងឆ្វេង) បង្ហាញពីសន្តិសុខម្នាក់នៅទីតាំង Park 8 ដែលជាទីតាំងមួយត្រូវបានអង្គការលើកលែងទោសអន្តរជាតិ កំណត់ថាជាទីតាំងប្រព្រឹត្តអំពើឆបោក ដែលមានលេខកូដ PV01។ រូបភាពនៅផ្នែកខាងស្ដាំខាងលើ បង្ហាញពីទីតាំងដែលវីដេអូនេះត្រូវបានថត ដោយផ្អែកលើរូបភាពពីផ្កាយរណប។ រូបភាពនៅផ្នែកខាងស្ដាំខាងក្រោម បង្ហាញពីឡូហ្គោរបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលអាចមើលឃើញនៅលើអាវយឺតរបស់សន្តិសុខនោះ។ ប្រភព៖ អង្គការលើកលែងទោសអន្តរជាតិ និងអ្នកប្រើប្រាស់ TikTok ឈ្មោះ PV001 (មិនមែនជាឈ្មោះអ្នកប្រើប្រាស់ពិតប្រាកដរបស់គាត់ទេ)។

ការរកឃើញទាំងនេះបង្ហាញថា **សមាជិកនៃកងកម្លាំងយោធា និងនគរបាលដែលកំពុងបំពេញការងារ បានចូលរួមដោយផ្ទាល់ក្នុងការផ្ដល់សន្តិសុខនៅតាមទីតាំងប្រព្រឹត្តអំពើឆបោកនានា ដែលជាកន្លែងមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។** ដោយសារតែបុគ្គលិកសន្តិសុខដើរតួនាទីយ៉ាងសំខាន់ក្នុងការឃុំឃាំង និងធ្វើបាបជនរងគ្រោះនៅខាងក្នុងទីតាំងទាំងនោះ ពួកគេអាចនឹងបានចូលរួមដោយផ្ទាល់ ជួយសម្រួល ឬត្រូវទទួលរ៉ាប់រងក្នុងការប្រព្រឹត្តការរំលោភបំពានទាំងនោះ។ ក្នុងន័យទូលំទូលាយជាងនេះ **ការរកឃើញទាំងនេះបង្ហាញយ៉ាងច្បាស់ថា ការឃុបឃិតគ្នារវាងអ្នកគ្រប់គ្រងទីតាំងទាំងនោះ និងមន្ត្រីរដ្ឋ បានជួយឱ្យសកម្មភាពទាំងនេះនៅតែបន្តកើតមាន ទោះបីជាអាជ្ញាធរបានធ្វើការបង្ក្រាបជាច្រើនលើក និងមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយក៏ដោយ។**

1.6 ក្របខ័ណ្ឌច្បាប់ និងការវិភាគ

ការស្រាវជ្រាវរបស់អង្គការលើកលែងទោសអន្តរជាតិបានរកឃើញថា **ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ ការប្រើប្រាស់កម្លាំងពលកម្មកុមារ ការធ្វើទារុណកម្ម និងការរំលោភបំពានផ្សេងទៀតដូចជា ការរំលោភសេពសន្ថវៈ ការដកហូតសេរីភាពដោយខុសច្បាប់ និងក្នុងករណីជាច្រើនទៀត គឺការដាក់ឱ្យធ្វើជាទាសករ បានបន្តកើតមានម្ដងហើយម្ដងទៀតនៅតាមទីតាំងប្រព្រឹត្តអំពើឆបោកនៅក្នុងប្រទេសកម្ពុជា។ ក្រុមសន្តិសុខដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាប្រព័ន្ធនៃការរំលោភបំពានទាំងនេះ។**

តាមរយៈកំណត់ត្រាអំពីទីតាំងប្រព្រឹត្តអំពើឆបោកនានាដែលអង្គការលើកលែងទោសអន្តរជាតិបានបង្ហាញថា ក្រុមសន្តិសុខគឺជាអ្នកទទួលជនរងគ្រោះពីការជួញដូរនៅពេលពួកគេមកដល់ គ្រប់គ្រងច្រកចេញចូល ទប់ស្កាត់ការរត់គេចខ្លួន ចាប់យកអ្នកដែលព្យាយាមរត់គេចខ្លួនមកវិញ បង្ខំឱ្យអនុវត្តការងារ នាំជនរងគ្រោះទៅកាន់កន្លែងដាក់ទណ្ឌកម្ម ធ្វើការវាយដំ ឬជួយសម្របសម្រួលឱ្យមានការវាយដំ និងការឆក់ដោយចរន្តអគ្គិសនី ព្រមទាំងតាមដានឃ្លាំមើលអ្នកដែលត្រូវបានឃុំខ្លួននោះជានិច្ច។

ទំនួលខុសត្រូវរបស់ក្រុមហ៊ុនសន្តិសុខ

សន្តិសុខ ដែលត្រូវបានជួលដោយក្រុមហ៊ុនសន្តិសុខទាំង៥ រួមមានក្រុមហ៊ុនសន្តិសុខលាភសំណាង ស៊ីឃ្យូរីធី ក្រុមហ៊ុនសន្តិសុខ ស៊ីឃ្យូរីធី វីស្ស៊ុន ក្រុមហ៊ុនសន្តិសុខ ហ្សេតឌី ស៊ីឃ្យូរីធី ក្រុមហ៊ុនសន្តិសុខ តារា ស៊ីឃ្យូរីធី និងក្រុមហ៊ុនសន្តិសុខ បេស ស៊ីឃ្យូរីធី ត្រូវបានរកឃើញថាមានជាប់ពាក់ព័ន្ធនឹងទីតាំងប្រព្រឹត្តអំពើឆបោកនានា ដែលអ្នកដែលបានរួចខ្លួនពីទីតាំងទាំងនោះបានរៀបរាប់ថាមានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ហើយការរំលោភបំពានទាំងនោះរួមមាន ការធ្វើទារុណកម្ម ពលកម្មដោយបង្ខំ ការឃុំខ្លួនដោយខុសច្បាប់ ការជួញដូរមនុស្ស និងការដាក់ឱ្យធ្វើជាទាសករ។ លើសពីនេះ មានករណីប្រើប្រាស់កម្លាំងពលកម្មកុមារនៅតាមទីតាំងដែលពាក់ព័ន្ធនឹងក្រុមហ៊ុន លាភសំណាង ស៊ីឃ្យូរីធី និង បេស ស៊ីឃ្យូរីធី ហើយមានករណីរំលោភផ្លូវភេទនៅទីតាំងមួយដែលពាក់ព័ន្ធនឹងក្រុមហ៊ុន ស៊ីឃ្យូរីធី វីស្ស៊ុន។ ផ្អែកលើភស្តុតាងទាក់ទងនឹងក្រុមហ៊ុនទាំងប្រាំនេះ គេអាចសន្និដ្ឋានបានថា សន្តិសុខទាំងនោះមិនត្រឹមតែបំពេញតួនាទីការពារសន្តិសុខនៅជុំវិញទីតាំងប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងជាតួអង្គសំខាន់ដែលធានាឱ្យមានការប្រព្រឹត្តអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរទាំងនោះទៀតផង។

ការរំលោភបំពានជាច្រើនដែលបានកត់ត្រានៅក្នុងរបាយការណ៍នេះ អាចចាត់ទុកជាឧក្រិដ្ឋកម្មទាំងក្រោមច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា។ បទល្មើសទាំងនោះរួមមាន បទល្មើសក្នុងការជួញដូរមនុស្ស ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការឃុំខ្លួនដោយខុសច្បាប់ និងការដាក់ឱ្យធ្វើជាទាសករ។ សន្តិសុខដែលបានប្រព្រឹត្តអំពើហិង្សាដោយផ្ទាល់ អាចត្រូវបានចាត់ទុកថាជាជនល្មើសផ្ទាល់។ ចំណែកឯអ្នកដែលអនុវត្តការឃុំខ្លួន រារាំងមិនឱ្យមានការរត់គេចខ្លួន នាំជនរងគ្រោះទៅកាន់បន្ទប់ដាក់ទណ្ឌកម្ម ឬឈរយាមក្នុងអំឡុងពេលដែលមានការរំលោភបំពាន គឺត្រូវបានចាត់ទុកថាបានផ្តល់ជំនួយ ដែលអាចចាត់ថ្នាក់ជាការសមគំនិត ឬជាការចូលរួមដោយចេតនាក្នុងបទល្មើសដែលប្រព្រឹត្តឡើងដោយក្រុមមួយដែលមានគោលបំណងរួមគ្នា។ សម្រាប់អ្នកគ្រប់គ្រង និងថ្នាក់ដឹកនាំនៃក្រុមហ៊ុនសន្តិសុខទាំងនេះ ពួកគេអាចនឹងត្រូវទទួលខុសត្រូវក្នុងនាមជាអ្នកមានឋានៈខ្ពស់ជាង។ លើសពីនេះ ក្រោមច្បាប់កម្ពុជា ក្រុមហ៊ុនសន្តិសុខទាំងនោះផ្ទាល់ក៏អាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌក្នុងនាមជាអង្គភាពដែលបានចុះបញ្ជីស្របច្បាប់ផងដែរ។ ការធ្វើទារុណកម្ម និងការដាក់ឱ្យធ្វើជាទាសករ គឺជាបទល្មើសក្រោមច្បាប់អន្តរជាតិ ដែលអាចត្រូវបានចាត់វិធានការផ្លូវច្បាប់ក្រោមគោលការណ៍យុត្តាធិការសកល។ ចំណែកឯបទល្មើសជួញដូរមនុស្សវិញ រដ្ឋដែលមានពលរដ្ឋជាជនរងគ្រោះ ឬជាជនល្មើស ក៏អាចចាត់វិធានការផ្លូវច្បាប់លើករណីទាំងនោះបានដែរ។

ទំនួលខុសត្រូវរបស់អាជ្ញាធរកម្ពុជា

ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ កម្ពុជាមានកាតព្វកិច្ចការពារបុគ្គលទាំងអស់ដែលនៅក្នុងដែនដីរបស់ខ្លួនពីការរំលោភសិទ្ធិមនុស្ស រួមទាំងការរំលោភបំពានដែលប្រព្រឹត្តដោយក្រុមហ៊ុនឯកជន។ កម្ពុជាក៏មានកាតព្វកិច្ចឆ្លើយតបប្រកបដោយប្រសិទ្ធភាពនៅពេលមានហេតុការណ៍បែបនេះកើតឡើង ដោយធ្វើការស៊ើបអង្កេតលើអង្គហេតុ នាំយកអ្នកដែលបានប្រព្រឹត្តបទល្មើសមកទទួលទោស និងធានាឱ្យមានដំណោះស្រាយ ឬសំណងសម្រាប់ជនរងគ្រោះ។ អង្គការលើកលែងទោសអន្តរជាតិបានសន្និដ្ឋានថា **កម្ពុជាបានបរាជ័យក្នុងការការពារជនរងគ្រោះពីការរំលោភបំពានទាំងនេះ។** ទោះបីជាមានភស្តុតាងជាច្រើនដែលបង្ហាញពីទំនាក់ទំនងរវាងក្រុមហ៊ុនសន្តិសុខ និងទីតាំងប្រព្រឹត្តអំពើឆបោកនានាដែលរកឃើញថាមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបានកើតមាននៅក្នុងទីតាំងទាំងនោះក៏ដោយ ក៏អង្គការលើកលែងទោសអន្តរជាតិ មិនបានឃើញមានការស៊ើបអង្កេតណាមួយទៅលើក្រុមហ៊ុនដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ ដែលរួមមានថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនទាំងនោះ ឬបណ្តាញពាក់ព័ន្ធផ្សេងទៀតឡើយ។ ការឆ្លើយតបរបស់រដ្ឋាភិបាលក៏មិនបានបង្ហាញពីការស៊ើបអង្កេតណាមួយក្នុងន័យនេះដែរ។

ភស្តុតាងទាំងនោះក៏បានបង្ហាញផងដែរអំពីការបរាជ័យក្នុងការគ្រប់គ្រងអ្នកផ្តល់សេវាសន្តិសុខឯកជន ការត្រួតពិនិត្យការប្រើប្រាស់អាវុធ ការស៊ើបអង្កេតលើទំនាក់ទំនងរវាងក្រុមហ៊ុនសន្តិសុខ និងសមាជិកកងកម្លាំងយោធា ឬប៉ូលិស ឬការនាំយកអ្នកដែលមានការពាក់ព័ន្ធនឹងឧស្សាហកម្មឆបោក មកទទួលខុសត្រូវតាមផ្លូវច្បាប់។

លើសពីនេះ ក្នុងករណីដែលមានសមាជិកកងកម្លាំងយោធា និងប៉ូលិសចូលរួមពាក់ព័ន្ធ ការទទួលខុសត្រូវរបស់កម្ពុជាមិនមែនកំណត់ត្រឹមតែជាការខកខានមិនបានអនុវត្តការយកចិត្តទុកដាក់ត្រឹមត្រូវ ប៉ុណ្ណោះទេ។ ក្រោមច្បាប់អន្តរជាតិដែលមានលក្ខណៈជាទំនៀមទម្លាប់ ឬបទដ្ឋានគតិយុត្តដែលត្រូវបានទទួលស្គាល់ជាសកល **សកម្មភាពរបស់មន្ត្រីប៉ូលិស និងយោធា ក្នុងនាមជាស្ថាប័នរបស់រដ្ឋ ត្រូវបានចាត់ទុកថាជាសកម្មភាពរបស់រដ្ឋ** ទោះបីជាពួកគេបានធ្វើលើសពីអំណាចរបស់ខ្លួន ឬល្មើសនឹងការណែនាំក៏ដោយ ដរាបណាសកម្មភាពនោះធ្វើឡើងក្នុងឋានៈជាមន្ត្រីរដ្ឋ ឬក្នុងលក្ខណៈដែលហាក់ដូចជាមានសិទ្ធិអំណាចផ្លូវការ។ ក្នុងករណីដែលមន្ត្រីរដ្ឋបានចូលរួម សម្របសម្រួល ឬការពារការរំលោភបំពាននៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោក ការទទួលខុសត្រូវរបស់កម្ពុជាមិនមែនមានត្រឹមតែជាការខកខានមិនបានអនុវត្តការយកចិត្តទុកដាក់ត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែជាការទទួលខុសត្រូវដោយផ្ទាល់ចំពោះការរំលោភបំពានទាំងនោះតែម្តង។ លើកលែងតែក្នុងករណីមួយចំនួនតូច ដូចជាការចាប់ខ្លួនលោក លី គួង (Ly Kuong) ជាដើម ក្រុមហ៊ុនជាច្រើន បុគ្គលដែលមានតួនាទីខ្ពស់ និងអ្នកដែលមានទំនាក់ទំនងនយោបាយផ្សេងទៀតដែលជាប់ពាក់ព័ន្ធនឹងឧស្សាហកម្មទីតាំងប្រព្រឹត្តអំពើឆបោក ហាក់ដូចជាមិនត្រូវបានប៉ះពាល់ដោយច្បាប់ឡើយ។ ស្ថានភាពនេះបានរួមចំណែកបង្កើតឱ្យមាននិទណ្ឌភាព (ភាពគ្មានទោសពៃរ៍) ដែលអាចអនុញ្ញាតឱ្យឧស្សាហកម្មនេះបន្តដំណើរការតទៅទៀតបាន។

នៅក្នុងលិខិតឆ្លើយតបទៅកាន់អង្គការលើកលែងទោសអន្តរជាតិ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៦ ក្រសួងមហាផ្ទៃកម្ពុជាបានបញ្ជាក់ថា ចន្លោះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៦ អាជ្ញាធរបាន «បង្ក្រាបទីតាំងប្រព្រឹត្តអំពើឆបោកតាមអនឡាញសរុបចំនួន ៨៣២កន្លែង» និងបានបញ្ជូន «ជនសង្ស័យចំនួន ៣ ៤៧៧នាក់ (ក្នុងនោះមានជនជាតិកម្ពុជាចំនួន ៤៩១នាក់) ព្រមទាំងសំណុំរឿងចំនួន ៤៤៦ ទៅកាន់តុលាការ»។ ក្រសួងបានលើកឡើងថា សកម្មភាពនេះបង្ហាញថាច្បាប់ត្រូវបានអនុវត្ត «ដោយមិនគិតពីឋានៈ ឬកម្រិតនៃការទទួលខុសត្រូវឡើយ រួមទាំងក្រុមហ៊ុន និងភ្នាក់ងារសន្តិសុខឯកជនផងដែរ»។ តួលេខទាំងនេះរួមមានសន្តិសុខចំនួន ១០នាក់ ដែលត្រូវបានបញ្ជូនទៅតុលាការក្រោយការបង្ក្រាបមួយនៅក្រុងប៉ោយប៉ែត និងភ្នាក់ងារសន្តិសុខឯកជនចំនួន ៦នាក់ ដែលត្រូវបានឃាត់ខ្លួនពីបទប្រើប្រាស់អាវុធខុសច្បាប់។ ក្រសួងក៏បានរាយការណ៍ផងដែរថា «មន្ត្រីនគរបាលចំនួន ៧៧នាក់ បានទទួលវិធានការវិន័យយ៉ាងតឹងរ៉ឹង» ហើយអង្គភាពប្រឆាំងអំពើពុករលួយបាន «ឃាត់ខ្លួនជនសង្ស័យចំនួន ១៧នាក់ ដែលជាមន្ត្រីនគរបាល មន្ត្រីយោធា និងមន្ត្រីរាជការ» ដោយបានបញ្ជូនសំណុំរឿងចំនួន ៤ ទៅកាន់តុលាការ ពាក់ព័ន្ធនឹងការឃុបឃិតជាមួយក្រុមឧក្រិដ្ឋជន។ ដោយចាត់ទុកវិស័យសន្តិសុខឯកជនថាជា «កម្លាំងគាំទ្រដល់នគរបាលជាតិ» ក្រសួងបានកំណត់ថា ការងារអាទិភាពមួយគឺ «ការពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យក្រុមហ៊ុនសន្តិសុខឯកជន [...] ដើម្បីទប់ស្កាត់កុំឱ្យសេវាកម្មសន្តិសុខត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងខុសច្បាប់»។

ទោះបីជាក្រសួងមហាផ្ទៃបានរាយការណ៍អំពីសកម្មភាពអនុវត្តច្បាប់យ៉ាងសកម្មក៏ដោយ ក៏លិខិតឆ្លើយតបនោះមិនបានបញ្ជាក់អំពីការស៊ើបអង្កេតណាមួយទៅលើក្រុមហ៊ុនសន្តិសុខ បុគ្គលិកយោធា និងនគរបាល ឬបណ្តាញអាជីវកម្មដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះឡើយ។ លើសពីនេះ ក៏មិនបានបង្ហាញដែរថា តើមានដាក់ទោសទណ្ឌ ឬកាត់ទោសណាមួយពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ការបង្ខំឱ្យធ្វើការ ឬការជួញដូរមនុស្សនោះទេ ហើយក៏មិនបានបញ្ជាក់ដែរថា តើមានជនរងគ្រោះពីអំពើជួញដូរមនុស្សស្ថិតនៅក្នុងចំណោមអ្នកដែលត្រូវបានចោទប្រកាន់តាមផ្លូវច្បាប់ដែរឬទេ។ ខ្លឹមសារទាំងស្រុងនៃលិខិតឆ្លើយតបនេះ ត្រូវបានដាក់បញ្ចូលនៅក្នុង**ឧបសម្ព័ន្ធ៣**។

1.7 សេចក្តីសន្និដ្ឋាន

ក្រុមហ៊ុនផ្តល់សេវាកម្មសន្តិសុខ និងបុគ្គលិកសន្តិសុខដែលត្រូវបានជួលដោយក្រុមឧក្រិដ្ឋកម្មឆ្លងដែន មានតួនាទីសំខាន់ណាស់សម្រាប់ដំណើរការនៃទីតាំងប្រព្រឹត្តអំពើឆបោក។ ក្រុមហ៊ុនទាំងនេះ និងបុគ្គលិករបស់ពួកគេ ក៏មានទំនាក់ទំនងយ៉ាងទូលំទូលាយជាមួយបណ្តាញផ្សេងទៀតផងដែរ រួមមានសមាជិកកងកម្លាំងយោធា និងនគរបាល បុគ្គលដែលមានឥទ្ធិពលនយោបាយ ព្រមទាំងបុគ្គលដែលមានអំណាចក្នុងវិស័យនយោបាយ និងធុរកិច្ច។ ទោះបីជាមានការរាយការណ៍ជាសាធារណៈអស់រយៈពេលជាច្រើនឆ្នាំមកហើយក្តី ក៏អាជ្ញាធរកម្ពុជាខកខានមិនបានធ្វើការស៊ើបអង្កេតលើក្រុមហ៊ុនទាំងនេះ ឬបណ្តាញការពារដែលនៅជុំវិញពួកគេនោះឡើយ។

ការទាមទារឱ្យមានការទទួលខុសត្រូវ គឺជារឿងចាំបាច់បំផុតសម្រាប់ជនរងគ្រោះ និងអ្នកដែលបានរួចខ្លួនពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ជនទាំងឡាយណាដែលបានប្រព្រឹត្ត សម្រួសម្រួល ឬបានចូលរួមដោយដឹងខ្លួននៅក្នុងការរំលោភបំពានទាំងនេះ ត្រូវតែត្រូវបានកំណត់អត្តសញ្ញាណ ហើយប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ដែលអាចទទួលយកបានតាមផ្លូវច្បាប់ ពួកគេត្រូវតែត្រូវបាននាំយកទៅកាត់ទោសនៅក្នុងដំណើរការជំនុំជម្រះដោយយុត្តិធម៌ (ដោយមិនមានការដាក់ទោសប្រហារជីវិតឡើយ)។ អ្នកដែលបានរួចខ្លួន ក៏ត្រូវទទួលបានវិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាព និងការផ្តល់សំណងពេញលេញពីសំណាក់ក្រុមហ៊ុនសន្តិសុខ និងរដ្ឋាភិបាលកម្ពុជា ដែលនេះជាការទទួលខុសត្រូវចំពោះការបរាជ័យក្នុងការការពារពួកគេ រួមទាំងករណីដែលមន្ត្រីរបស់រដ្ឋផ្ទាល់បានចូលរួមក្នុងការរំលោភបំពានទាំងនោះផងដែរ។

ការទាមទារឱ្យមានការទទួលខុសត្រូវបែបនេះ ក៏ជាកត្តាដែលមិនអាចខ្វះបានសម្រាប់រាល់កិច្ចខិតខំប្រឹងប្រែងដែលផ្តល់ភាពជឿជាក់ និងនិរន្តរភាព ក្នុងគោលបំណងបញ្ឈប់ឧស្សាហកម្មទីតាំងប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធអនឡាញនៅក្នុងប្រទេសកម្ពុជា។ ទោះបីជាប្រតិបត្តិការចុះបង្ក្រាបអាចរំខានដល់ដំណើរការរបស់ទីតាំងប្រព្រឹត្តអំពើឆបោកទាំងនោះជាបណ្តោះអាសន្ន ជួយរំដោះជនរងគ្រោះ ពេលខ្លះឈានដល់ការបិទទីតាំង ឬបង្ខំឱ្យក្រុមឧក្រិដ្ឋជនផ្លាស់ប្តូរទីតាំងក៏ដោយ ប៉ុន្តែប្រសិនបើគ្មានការស៊ើបអង្កេតស៊ីជម្រៅបន្ថែមទៀតទេនោះ វានឹងមិនអាចរំលាយចោលនូវហេដ្ឋារចនាសម្ព័ន្ធសន្តិសុខ និងបណ្តាញការពារដែលឧស្សាហកម្មនេះពឹងផ្អែកលើនោះឡើយ ហើយឧស្សាហកម្មទីតាំងប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធអនឡាញនេះក៏អាចនឹងវិលត្រឡប់មកដំណើរការឡើងវិញបានដែរ។

1.8 អនុសាសន៍

ជូនចំពោះអាជ្ញាធរកម្ពុជា

- ធ្វើការស៊ើបអង្កេតជាបន្ទាន់ ដោយឯករាជ្យ និងមិនលំអៀង ព្រមទាំងផ្តល់ធនធានគ្រប់គ្រាន់ ក្នុងការស៊ើបអង្កេតទៅលើតួនាទីរបស់ក្រុមហ៊ុនសន្តិសុខឯកជននៅក្នុងឧស្សាហកម្មទីតាំងប្រព្រឹត្តអំពើឆបោកក្នុងប្រទេសកម្ពុជា រួមទាំងក្រុមហ៊ុនដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ និងក្រុមហ៊ុនផ្សេងទៀតដែលកំពុងប្រតិបត្តិការនៅក្នុងទីតាំងប្រព្រឹត្តអំពើឆបោកទាំងនោះ។

- ផ្អាកអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនសន្តិសុខទាំងឡាយណាដែលមានភស្តុតាងគួរឱ្យជឿជាក់ថាបានពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ រហូតទាល់តែមានការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ហើយត្រូវដកហូតអាជ្ញាប័ណ្ណចោលប្រសិនបើរកឃើញថាក្រុមហ៊ុនទាំងនោះបានប្រព្រឹត្ត បានសម្របសម្រួល ឬបានចូលរួមដោយដឹងខ្លួនក្នុងការរំលោភសិទ្ធិមនុស្ស។

- ធ្វើការស៊ើបអង្កេតលើសមាជិកទាំងអស់នៃកងយោធពលខេមរភូមិន្ទ (RCAF) នគរបាលជាតិកម្ពុជា កងរាជអាវុធហត្ថ និងស្ថាប័នសន្តិសុខរដ្ឋ ឬស្ថាប័នអនុវត្តច្បាប់ផ្សេងទៀតទាំងឡាយណា ដែលមានការសង្ស័យគួរឱ្យជឿជាក់ថា ជាម្ចាស់

អ្នកគ្រប់គ្រង អ្នកជ្រើសរើសបុគ្គលិក អ្នកបណ្តុះបណ្តាល អ្នកត្រួតពិនិត្យ ឬជាបុគ្គលិកធ្វើការឱ្យក្រុមហ៊ុនសន្តិសុខឯកជនដែលមានជាប់ពាក់ព័ន្ធនឹងទីតាំងប្រព្រឹត្តអំពើឆបោក។

- ធ្វើការស៊ើបអង្កេតដោយទូលាយលើបណ្តាញដែលជួយសម្រួលដល់ដំណើរការនៃទីតាំងប្រព្រឹត្តអំពើឆបោក រួមមាន ក្រុមហ៊ុនសន្តិសុខ កាស៊ីណូ ម្ចាស់អចលនទ្រព្យ អ្នកអភិវឌ្ឍន៍អចលនទ្រព្យ អ្នកជ្រើសរើសបុគ្គលិក មនុស្សមួយចំនួនក្នុងវិស័យហិរញ្ញវត្ថុ អ្នកផ្តល់សេវាទូរគមនាគមន៍ និងបុគ្គលដែលមានឥទ្ធិពលនយោបាយ។

ជូនចំពោះក្រុមហ៊ុនសន្តិសុខឯកជនដែលកំពុងប្រតិបត្តិការនៅកម្ពុជា

- បញ្ឈប់ជាបន្ទាន់នូវការផ្តល់សេវាកម្មនៅទីតាំងណាមួយដែលមានការឃុំខ្លួនដោយខុសច្បាប់ ការជួញដូរមនុស្ស ការបង្ខំឱ្យធ្វើការ ការធ្វើទារុណកម្ម ឬការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរផ្សេងទៀត។
- ផ្តល់ ឬចូលរួមផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភសិទ្ធិមនុស្សទាំងអស់ដែលទទួលរងគ្រោះដោយជនរងគ្រោះដោយសារក្រុមហ៊ុនសន្តិសុខ។

ជូនចំពោះរដ្ឋាភិបាលបរទេស និងសហគមន៍អន្តរជាតិ

- ជំរុញឱ្យកម្ពុជាធ្វើការស៊ើបអង្កេតជាបន្ទាន់ ដោយមិនលំអៀង និងឯករាជ្យ ទៅលើក្រុមហ៊ុន ថ្នាក់ដឹកនាំក្រុមហ៊ុន និងមន្ត្រីរដ្ឋ ដែលមានជាប់ពាក់ព័ន្ធនឹងទីតាំងប្រព្រឹត្តអំពើឆបោក តាមរយៈយន្តការជាតិ និងអន្តរជាតិ ជាជាងការវាយតម្លៃវឌ្ឍនភាពដោយផ្អែកលើចំនួននៃការចុះបង្ក្រាប ការចាប់ខ្លួន ឬការបណ្តេញជនបរទេសចេញពីប្រទេស។
- ពិនិត្យឡើងវិញនូវកិច្ចសហប្រតិបត្តិការលើវិស័យអនុវត្តច្បាប់ យោធា ហិរញ្ញវត្ថុ និងសន្តិសុខ ជាមួយស្ថាប័ន និងបុគ្គលនៅកម្ពុជា ដែលមានភស្តុតាងគួរឱ្យជឿជាក់ថាបានជួយសម្រួល ឬការពារទីតាំងប្រព្រឹត្តអំពើឆបោក។
- អនុវត្តយុត្តាធិការ—រួមទាំងយុត្តាធិការសកល ឬយុត្តាធិការផ្សេងទៀតដែលគ្របដណ្តប់លើករណីក្រៅដែនដី (ក្នុងករណីដែលអាចធ្វើទៅបាន)—ទៅលើក្រុម ក្រុមហ៊ុន និងបុគ្គលនានា ដែលត្រូវបានសង្ស័យថាមានការទទួលខុសត្រូវចំពោះបទល្មើសនានាតាមច្បាប់អន្តរជាតិ ដែលពាក់ព័ន្ធនឹងឧស្សាហកម្មទីតាំងប្រព្រឹត្តអំពើឆបោកតាមប្រព័ន្ធអនឡាញ ហើយប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ដែលអាចទទួលយកបានតាមផ្លូវច្បាប់ នោះត្រូវចេញដីកាចាប់ខ្លួន។

AMNESTY INTERNATIONAL IS A GLOBAL MOVEMENT FOR HUMAN RIGHTS. WHEN INJUSTICE HAPPENS TO ONE PERSON, IT MATTERS TO US ALL.

Contact us

info@amnesty.org

+44 (0)20 7413 5500

Join the conversation

www.facebook.com/AmnestyGlobal

@Amnesty

OFFICIAL BUSINESS

SECURITY COMPANIES AND AUTHORITIES AT SCAMMING COMPOUNDS IN CAMBODIA

សេចក្ដីសង្ខេប

Amnesty International’s new report shows how private security companies were central to the operation of Cambodia’s scamming compounds and the serious human rights abuses committed within them. Drawing on research across 86 compounds, interviews with more than 150 survivors, site visits, social media analysis and other evidence, Amnesty International found that guards were not merely protecting premises but playing key roles in confining trafficked people, preventing escape, enforcing forced labour, and, in some cases, directly participating in torture and other ill-treatment. The report identifies five security companies linked to at least 23 scamming compounds and documents evidence connecting some of these companies to politically connected business actors, military personnel and police officers.

The report further finds links between serving members of the Cambodian military and police and at least 22 scamming compounds, raising concerns about official complicity and the failure of authorities to effectively dismantle the industry despite repeated crackdowns. Amnesty International concludes that security companies, individual guards, company executives and relevant state actors should be investigated for their possible role in trafficking, torture, deprivation of liberty, enslavement and other crimes. It calls on the Cambodian government to investigate security companies and state officials linked to the compounds, hold those responsible accountable, provide remedies to victims and survivors and address the wider networks of protection and support that enabled the scamming industry to flourish.

INDEX: ASA 23/1569/2026
OCTOBER 2026
LANGUAGE: KHMER

amnesty.org

AMNESTY INTERNATIONAL